នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Nov-2012, 15:33
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ ជាមួយឧបសម្ព័ន្ធសម្ងាត់ II**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បណ្តឹងសាទុក្ខតាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II)**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះតុលាការកំពូល:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រីម, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម A. KLONOWIECKA-MILART | អៀង សារី |
| | ចៅក្រម សោម សិរីវឌ្ឍ | ខៀវ សំផន |
| | ចៅក្រម C. N. JAYASINGHE | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | ចៅក្រម ម៉ុង មុន្នីចរិយា | លោក សុន អរុណ |
| | ចៅក្រម យ៉ា ណារិន | លោក Michiel PESTMAN |
| | ចៅក្រម Florence Ndepele MUMBA | លោក Victor Koppe |
| | **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក អាង ឧត្តម |
| | ពេជ អង្គ | លោក Michael G.KARNAVAS |
| | Elisabeth SIMONNEAU FORT | លោក គង់ សំអុន |

លោក Anta GUISSE

លោក Arthur VERCKEN

លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន ១០៤, ១០៥, ១០៦(២), និង១០៧ នៃវិធានផ្ទៃក្នុង ("វិធាន")[1] សហព្រះរាជអាជ្ញាសូមដាក់នូវបណ្តឹងសាទុក្ខភ្លាមៗមួយ ("បណ្តឹងសាទុក្ខ") ជូនអង្គជំនុំជម្រះតុលាការកំពូល "អង្គជំនុំជម្រះ" ប្រឆាំងនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ ("ឯកសារលេខ E163") និងពេលវេលាកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ពាក់ព័ន្ធនឹងច្បាប់ដែលអាចអនុវត្តបាន ("សេចក្តីសម្រេចដែលរងការជំទាស់")[2]។

២- សេចក្តីសម្រេចដែលរងការជំទាស់ ប្រសិនជាមិនបានកែប្រែទេនោះ នឹងកើតមាននៅសវនាការជំនុំជម្រះ និងកេរ្តិ៍ដំណែលមួយដែលបរាជ័យ ដោយសារមិនបានបង្ហាញឲ្យបានគ្រប់គ្រាន់អំពីឧក្រិដ្ឋកម្មដែលមានច្រើន និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាមានការព្រួយបារម្ភខ្លាំងថា អនាគតនៃសវនាការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ០០២ដែលត្រូវធ្វើតទៅមុខទៀតដែលអាចនឹងរួមបញ្ចូលនូវការចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មបន្ថែមថ្មីទៀត គឺស្ថិតនៅឆ្ងាយណាស់។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ការអនុវត្តនូវឆន្ទានុសិទ្ធិ ដើម្បីកម្រិតវិសាលភាពនៃសវនាការ នៅពេលដែលឈានទៅដល់ការពន្យារពេល គឺបានឈានហួសពីការកំណត់ត្រឹមត្រូវស្ថិតនៅក្នុងកាលៈទេសៈនេះ និងពឹងផ្អែកទៅលើសេចក្តីសម្អាងផ្នែកច្បាប់ និងអង្គហេតុដែលមិនត្រឹមត្រូវ។

៣- ដោយសារមូលហេតុដូចដែលបានលើកឡើងខាងក្រោមនេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា៖ (១)បណ្តឹងសាទុក្ខនេះអាចទទួលយកបាន (២)សេចក្តីសម្រេចដែលរងការជំទាស់មានកំហុសច្បាប់ កំហុសអង្គហេតុ និង/ឬកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង (៣) សេចក្តីសម្រេចដែលរងការជំទាស់ គួរតែត្រូវបានកែប្រែ ដើម្បីដាក់បញ្ចូល**មន្ទីរសន្តិសុខស-២១** (និងទីតាំងសម្លាប់មនុស្សនៅជើងឯក) ព្រមទាំង ទីតាំងសម្លាប់នៅ**ស្រុកកំពង់ត្រឡាចលើ (ស្រុក១២)** ដែល

---

[1] អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨), ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី៣ សីហា ២០១១ ("វិធាន")។

[2] ឯកសារ **E163/5** ("សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឱ្យដាក់បញ្ចូលបន្ថែមនូវទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងរង្វង់នៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារលេខ E163) និងកាលបរិច្ឆេទកំណត់សម្រាប់ការដាក់សារណាលើផ្នែកស្តីពីច្បាប់ជាធរមាន នៃសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល") ចុះថ្ងៃទី៨ តុលា ២០១២ ("សេចក្តីសម្រេចដែលរងការជំទាស់")។

សហព្រះរាជអាជ្ញាបានស្នើសុំ នៅក្នុងឯកសារលេខE163 ដែលឋិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១។

## II. ប្រវត្តិនីតិវិធី

៤- កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៩*ស្ទួនពីរ* បានបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០២ ទៅជាវគ្គនៃសវនាការជំនុំជម្រះក្តីជាច្រើនដាច់ដោយឡែកៗពីគ្នាដែលជាពិសេស មានរួមបញ្ចូលក្នុងនោះនូវការចោទប្រកាន់ទាក់ទងនឹងអង្គហេតុ និងអង្គច្បាប់ (ដីកាបំបែកកិច្ចនីតិវិធី)[3]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា៖

*...នៅក្នុងដំណាក់កាលណាមួយក៏បាន អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ចំពោះសិទ្ធិរបស់មេធាវីដែលត្រូវទទួលបានក្នុងការរៀបចំការពារឲ្យបានដោយប្រសិទ្ធភាព ហើយភាគីទាំងនោះត្រូវទទួលបានការជូនដំណឹងនៅក្នុងរយៈពេលសមស្រប[4]* ។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសវនាការលើកដំបូង (សំណុំរឿងលេខ០០២/០១) នូវបញ្ហាអង្គហេតុសំខាន់ៗជាច្រើន ដែលបានកាត់ចេញពីសំណុំរឿងលេខ០០២ ទាំងមូល ដូចជា ប្រវត្តិ និងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ, តួនាទីរបស់ជនជាប់ចោទ នៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ, ខ្សែរយៈនៃការប្រាស្រ័យទាក់ទង, និងគោលនយោបាយឧក្រិដ្ឋទាំងប្រាំដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[5]។ អនុលោមតាមដីកាបំបែកកិច្ចនីតិវិធី ការកំណត់វិសាលភាពនៃ សវនាការជំនុំជម្រះក្តីនេះ ទាក់ទងជាចំបងទៅនឹង៖ (i) ពង្រីកត្រឹមដែលគោលនយោបាយឧក្រិដ្ឋ នឹងទាក់ទងនឹងសំណុំរឿងលេខ០០២/០១ (ក្នុងខណៈដែលការរីកចំរើនគោលនយោបាយឧក្រិដ្ឋទាំងប្រាំត្រូវបានដាក់បញ្ចូល គឺមានតែ*ការអនុវត្ត*នូវគោលនយោបាយទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញដោយបង្ខំតែប៉ុណ្ណោះដែលត្រូវតែពិចារណា)[6] និង(ii)

---

[3] ឯកសារលេខ **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន *៨៩ស្ទួនពីរ*, ចុះថ្ងៃទី២២ កញ្ញា ២០១១ (“ដីកាបំបែកកិច្ចដំណើរការនីតិវិធី”)។

[4] ឯកសារលេខ **E124** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី៦។

[5] ឯកសារលេខ **E124/7.1**/កែតម្រូវ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសវនាការមួយក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ (បញ្ជីដើមនៃកថាខណ្ឌពាក់ព័ន្ធបន្ទាប់ពីមានដីកាបំបែកកិច្ចនីតិវិធី) ត្រង់កថាខណ្ឌទី១ និង៣។

[6] ឯកសារលេខ **E141** ចម្លើយតបទៅនឹងបញ្ហាដែលបានលើកឡើង ដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅថ្ងៃទី១៨ វិច្ឆិកា ២០១១,ថ្ងៃទី១៧ វិច្ឆិកា២០១១ , ទំព័រ២។

ទីតាំងឧក្រិដ្ឋកម្មជាក់លាក់នានាដែលត្រូវលើកឡើង (មានតែ"ការជម្លៀសប្រជាជនចេញដំណាក់កាលទី១ និងទី២" តែប៉ុណ្ណោះ)[7]។

៥- កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានស្នើទៅអង្គជំនុំជម្រះសាលាដំបូងឲ្យពិនិត្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងឲ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្មថ្មីបន្ថែមចំនួន៩ទៀតដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១[8]។ សំណើនេះរបស់សហព្រះរាជអាជ្ញាត្រូវបានជំទាស់ដោយ នួន ជា[9] ហើយមានការគាំទ្រពី អៀង សារី (ចំពោះសំណើរបស់គាត់ដែលសុំឲ្យធ្វើសវនាការដោយផ្ទាល់មាត់ និងជាសាធារណៈតែប៉ុណ្ណោះ)[10]។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា ដោយការជូនដំណឹងរបស់ខ្លួនផ្ទាល់ស្នើសុំឲ្យមានការពិចារណាឡើងវិញទៅលើដីកាបំបែកកិច្ចនីតិវិធី កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១[11]។ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា (និងដើមបណ្តឹងរដ្ឋប្បវេណី) (សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញ)[12]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានបញ្ជាក់ថា៖

> *អង្គជំនុំជម្រះសាលាដំបូង មិនបានបដិសេធចោលនូវលទ្ធភាពការដាក់បន្ថែមការចោទប្រកាន់ ឬបទចោទ នៅក្នុងការជំនុំជម្រះដំណាក់កាលទីមួយក្នុងសំណុំរឿង០០២ឡើយក្នុងកាលៈទេសៈអនុញ្ញាត។ អង្គជំនុំជម្រះកត់សម្គាល់អំពីការបញ្ជាក់របស់សហព្រះរាជអាជ្ញា នៅក្នុងសំណើសុំរបស់ខ្លួនអំពីបរិបទបន្ថែមដែលអាចមាន សម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះក្តីដំណាក់កាលទីមួយ ហើយអង្គជំនុំជម្រះត្រូវបានណែនាំ*

---

[7] ឯកសារលេខ **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌទី៥។

[8] ឯកសារលេខ **E124/2** សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ*, ចុះថ្ងៃទី៣ តុលា ២០១១។

[9] ឯកសារលេខ **E124/5** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី១១ តុលា ២០១១។

[10] ឯកសារលេខ **E124/3** ការគាំទ្រដោយមានលក្ខខណ្ឌរបស់លោក អៀង សារី ចំពោះសេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញនូវលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ*", ចុះថ្ងៃទី៣ តុលា ២០១១។

[11] ឯកសារលេខ **E124/4** សំណើរបស់សហមេធាវីនាំមុខ និងមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឯកសារលេខ E124/8, ចុះថ្ងៃទី១៨ តុលា ២០១១។

[12] ឯកសារលេខ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ **E124/2**) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ត្រង់កថាខណ្ឌទី១២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។

*ដោយការយល់ឃើញរបស់ខ្លួនចំពោះ ជាការចោទប្រកាន់ជាអាទិភាពសម្រាប់ពិចារណា ក្នុងដំណាក់កាលជំនុំជម្រះក្រោយៗទៀត*[13]

៦- ដោយបានកត់សម្គាល់ចំពោះពាក្យពេចន៍នៃសេចក្តីសម្រេចនេះ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចូលទីតាំងឧក្រិដ្ឋកម្មចំនួនបី ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មប្រាំបួនដូចយោងខាងលើ ស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តី ក្នុងសំណុំរឿងលេខ00២/0១[14]។ សំណើនេះត្រូវបានជំទាស់ដោយ អៀង សារី[15] និងខៀវ សំផន[16]។

៧- តាមរយៈអនុស្សរណៈចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់សំណើរបស់សហព្រះរាជអាជ្ញា និងបានបញ្ជាក់ថាខ្លួនៈ "អាច តាមរយៈញត្តិរបស់ខ្លួនផ្ទាល់ សម្រេចនៅក្នុងពេលវេលាមួយសមស្រប ដើម្បីពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីក្នុងសំណុំរឿងលេខ00២/0១ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិក្នុងការរៀបចំសវនាការរបស់ខ្លួន"[17]។

៨- កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះបានជូនដំណឹងដល់គ្រប់ភាគីទាំងអស់នៃអង្គប្រជុំរៀបចំសវនាការ("TMM") ដែលត្រូវបានធ្វើឡើង ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង00២/0១ និងដើម្បីផ្តល់ការជូនដំណឹងសម្រាប់វិធានការណ៍ផ្សេងៗបន្តទៀត ក្នុងគោលបំណងធ្វើឲ្យដំណើរការនីតិវិធីនៅក្នុងសវនាការបានឆាប់រហ័ស"[18]។ ដោយបានពិចារណា មិនគ្រាន់តែសម្រេចបញ្ចប់លើសំណើរបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ដែលសុំឲ្យពង្រីកវិសាលភាពនៃសវនាការជំនុំជម្រះក្តីនោះប៉ុណ្ណោះទេ អង្គជំនុំជម្រះបានបង្ហាញថាខ្លួន "មានឆន្ទៈចង់គិតពិចារណា" ដើម្បី "ធ្វើការពង្រីកក្នុងទំហំជាមធ្យមមួយ" ដើម្បីដាក់បញ្ចូលនូវការសម្លាប់ប្រជាជនជម្លៀសនៅស្រុក១២ និងអតីតពួកទាហាន និងមន្ត្រី

---

[13] ឯកសារលេខ **E124/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី១២។

[14] ឯកសារលេខ **E163** សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង00២/0១ ចុះថ្ងៃទី២៧ មករា ២០១២។

[15] ឯកសារលេខ **E163/1** ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង00២/0១, ចុះថ្ងៃទី0៣ ខែកុម្ភៈ ឆ្នាំ២០១២។

[16] ឯកសារលេខ **E163/4** ចម្លើយតបរបស់ ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងនៃសំណុំរឿង00២, ចុះថ្ងៃទី១៧ កុម្ភៈ ២០១២។

[17] ឯកសារលេខ **E172** "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះ នឹងស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ00២/0១", ចុះថ្ងៃទី១៧ កុម្ភៈ ២០១២, ត្រង់កថាខណ្ឌទី៩។

[18] ឯកសារលេខ **E218** "ការកំណត់កាលបរិច្ឆេទកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង00២/0១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពសវនាការ", ចុះថ្ងៃទី៣ សីហា ២០១២។

របស់ លន់ នល់ នៅទួលពោធិ៍ជ្រៃ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ ព្រមទាំងតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯក ហើយបានស្នើឲ្យដាក់សារណាជាក់លាក់នៅលើចំណុចនេះ[19]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ផងដែរថា ខ្លួន "យល់ស្របជាមួយសហព្រះរាជអាជ្ញាថាការដាក់បន្ថែមនូវទីតាំងដែលស្នើបន្ថែមថ្មីទាំងនេះ អាចស្របទៅតាមលំដាប់លំដោយនៃពេលវេលានិងតក្កភាពនៃព្រឹត្តិការណ៍នានាដែលត្រូវធ្វើសវនាការនៅក្នុងសំណុំរឿងលេខ០០២/០១"[20]។

៩- នៅមុនពេលបើកកិច្ចប្រជុំរៀបចំសវនាការ("TMM") សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះ ថា ការដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្ម នៅមន្ទីរស-២១, ស្រុក១២, និងទួលពោធិ៍ជ្រៃ អាចជួយច្រើនដល់សហព្រះរាជអាជ្ញា ក្នុងការដាក់បន្ទុកដោយការបង្ហាញភ័ស្តុតាងរបស់ខ្លួន ដោយការផ្តល់នូវ "ភ័ស្តុតាងរឹងមាំអំពីចេតនាឧក្រិដ្ឋដែលស្ថិតនៅពីក្រោយការជម្លៀសប្រជាជនដោយបង្ខំ"[21]។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថាសាក្សីពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះ "នៅក្នុងករណីណាក៏ ត្រូវតែបានស្តាប់ដោយអង្គជំនុំជម្រះ ជាផ្នែកមួយនៃភ័ស្តុតាងរបស់សហព្រះរាជអាជ្ញាអំពីគោលបំណងពិតប្រាកដដែលនៅពីក្រោយការជម្លៀសថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"[22]។ គោលជំហរនេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងពេលប្រជុំ TMM[23]។ អង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របតាមអំណះអំណាងនេះ និងបានធ្វើការសម្រេចបញ្ចប់សំណើសុំរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ តាមរយៈសេចក្តីសម្រេចដែលរងការជំទាស់។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកខ្លួនឯងថា "មិនអាចពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីនេះ.. ក្នុងការដាក់បញ្ចូលនូវការចោទប្រកាន់ទាក់ទងនឹងអង្គហេតុដែលពាក់ព័ន្ធនឹងមន្ទីរស-២១ និងស្រុក២១ បានទេ"[24] ក៏ប៉ុន្តែបញ្ចូលនៅក្នុងវិសាលភាពនៃការជំនុំ

---

[19]ឯកសារលេខ **E218** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី១៣, ១៥។ ឯកសារលេខ E218.1 ឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងអនុស្សរណៈស្តីពី "សំណើរបស់សហព្រះរាជអាជ្ញាសុំពង្រីកវិសាលភាពនៃសវនាការក្នុងសំណុំរឿងលេខ ០០២/០១ (ឯកសារលេខ E163), ចុះថ្ងៃទី៣ សីហា ២០១២។

[20]ឯកសារលេខ E218.1 ឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងអនុស្សរណៈស្តីពី "សំណើរបស់សហព្រះរាជអាជ្ញាសុំពង្រីកវិសាលភាពនៃសវនាការ ក្នុងសំណុំរឿងលេខ០០២/០១ (ឯកសារលេខ E163), ចុះថ្ងៃទី៣ សីហា ២០១២ , កថាខណ្ឌទី៣។

[21] ឯកសារលេខ **E218/2** សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាគន្លឹះនានាដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ សីហា ២០១២ ( ដោយមានឧបសម្ព័ន្ធ ការសម្ងាត់ ក ភ្ជាប់មកជាមួយ), ចុះថ្ងៃទី១៥សីហា ២០១២, ត្រង់កថាខណ្ឌទី២០។

[22]ឯកសារលេខ **E218/2** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី២១។

[23] ឯកសារលេខ **E1/114.1** ប្រតិចារិក, ចុះថ្ងៃទី១៧ សីហា ២០១២, ពីកថាខណ្ឌទី៩៥ -១០២។

[24] ឯកសារលេខ **E163/5** អនុស្សរណៈដែលមានចំណងជើងថា " សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០១ (ឯកសារលេខ E១៦៣) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន" , ចុះថ្ងៃទី៨ តុលា ២០១២ ត្រង់កថាខណ្ឌទី២។

ជម្រះក្ដីអំពីការសម្លាប់ទាំងឡាយនៅទួលពោធិ៍ជ្រៃ ដែល "បានកើតឡើងភ្លាមៗបន្ទាប់ពីការជម្លៀសចេញពីក្រុងភ្នំពេញ"[25]។ អង្គជំនុំជម្រះសាលាដំបូងក៏បានដាក់បញ្ចូលផងដែរនូវការពិចារណាអំពីការអនុវត្តគោលនយោបាយដែលបានចោទប្រកាន់ទាក់ទងទៅនឹង "ការប្រព្រឹត្តិទៅលើក្រុមគោលដៅ" នៅក្នុងសំណុំរឿងលេខ០០២/០១ ប៉ុន្តែដែលរហូតមកដល់ពេលនេះ ជាប់ពាក់ព័ន្ធនឹងគោលដៅគឺអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[26]។ កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងអនុស្សរណៈដាច់ដោយឡែកមួយថា "គ្មានការពង្រីកវិសាលភាពនៃការជំនុំជម្រះក្ដី នៅក្នុងសំណុំរឿងលេខ០០២/០១ បន្ថែមទៀតទេ ដែលមាននៅក្នុងឯកសារ(163/5)"[27]។

## III. ភាពអាចទទួលយកបាន

១០- សេចក្ដីសម្រេចដែលរងការជំទាស់នេះ ត្រូវបានប្ដឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤.៤.ក ដែលអនុញ្ញាតឲ្យធ្វើបណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹង "សេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"។ វាមានហេតុផលដើម្បីសន្និដ្ឋានថា សេចក្ដីសម្រេចដែលរងការជំទាស់នេះមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងនឹង៖ (១)ការសម្លាប់ប្រជាជនជម្លៀសនៅតាមទីតាំងនានាក្នុងស្រុក១២, និង (២)មន្ទីរសន្តិសុខ ស-២១ និងទីតាំងសម្លាប់មនុស្ស ដែលពាក់ព័ន្ធនឹងមន្ទីរនេះគឺជើងឯក។ ការមិនដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងអស់នេះនៅក្នុងសំណុំរឿងលេខ០០២/០១ និងមិនអាចមានសវនាការជាបន្តបន្ទាប់ទៀតនៅក្នុងសំណុំរឿងលេខ០០២ បានធ្វើឲ្យសេចក្ដីសម្រេចដែលរងការជំទាស់នេះ ស្ថិតនៅក្នុងរបត់នៃយុត្តិសាស្ត្រពីមុនៗរបស់អង្គជំនុំជម្រះពិតប្រាកដ ដែលអនុញ្ញាតឲ្យមានបណ្ដឹងសាទុក្ខភ្លាមៗ តាមវិធាន ១០៤.៤.ក។

### ក. វិធាន ១០៤.៤.ក បង្ហាញពីការពិនិត្យបណ្ដឹងសាទុក្ខឡើយវិញ នៅក្នុងកាលៈទេសៈដែលលទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនៅពេលអនាគត គឺឋិតនៅឆ្ងាយ មិនអាចមើលឃើញបាន

[25] ឯកសារលេខ**E163/5** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី៣។

[26] **E124/7.3** បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១ (E163), ត្រង់កថាខណ្ឌទី១(vii)។

[27] ឯកសារលេខ **E223/2** អនុស្សរណៈ: សវនាការដេញដោលលើឯកសារពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ពន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារលេខ E208/4 ) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារលេខ E223), ចុះថ្ងៃទី១៩ តុលា ២០១២។

១១- អង្គជំនុំជម្រះបានរកឃើញពីមុនថាវិធាន១០៤.៤.ក ត្រូវតែជាកម្មវត្ថុនៃ "ការបកស្រាយសមហេតុផលមួយ"[28] តាមស្មារតីរបស់វិធាននេះ ជាជាងការបកស្រាយដែលមានលក្ខណៈតឹងរ៉ឹង។ ការបកស្រាយរបស់អង្គជំនុំជម្រះចំពោះវិធាន១០៤.៤.ក បានសម្រេចដោយបញ្ចូល ទាំងសម្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូង ទោះជាគ្មានតម្លៃជាផ្លូវការអំពីការបញ្ចប់តាមផ្លូវច្បាប់នូវ "កិច្ចដំណើរការនីតិវិធី" យ៉ាងណាក៏ដោយ "មិនមានការសន្យាច្បាស់លាស់អំពីការបន្តកិច្ចដំណើរការនីតិវិធី និងដូច្នេះគឺពិតជាមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"[29]។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា ក្នុងករណីមានផលវិបាកដែលស្តែងចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលធ្វើឱ្យស្ទះដល់ដំណោះស្រាយផ្លូវច្បាប់បន្ថែមទៀតនោះ គឺមាន "កម្រិតធ្ងន់ធ្ងរគ្រប់គ្រាន់ហើយ" និងភ្ជាប់ក្តីកង្វល់ដដែលនោះថាជាការបញ្ចប់កិច្ចដំណើរការនីតិវិធី នោះបណ្តឹងសាទុក្ខភ្លាមៗអាចធ្វើទៅបាន[30]។ ដូចអង្គជំនុំជម្រះបានកត់សម្គាល់ថា ការបកស្រាយនេះ "ត្រូវបានបញ្ជាក់អះអាងតាមរយៈការជ្រើសរើសពាក្យពេចន៍ជាក់លាក់នៅក្នុងវិធាន១០៤.៤.ក នៃវិធានផ្ទៃក្នុង។ "*អានុភាពប*ញ្ចប់កិច្ចដំណើរការនីតិវិធី") គឺខុសគ្នាពីសេចក្តីសម្រេចដែលបញ្ចប់កិច្ចដំណើរការនីតិវិធី"[31]។ ជាលទ្ធផល ការបញ្ចប់កិច្ចដំណើរការនីតិវិធីត្រូវតែបកស្រាយឱ្យបានសមហេតុផល ដោយបញ្ចូលបញ្ហាទាំងឡាយដែលបានរារាំងមកដល់ពេលនេះ ទៅជាមានភាពមិនច្បាស់លាស់ នៅពេលអនាគតដែលមានឱកាសបន្តិចបន្តួចសម្រាប់សវនាការ។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា គឺថាការបកស្រាយណាមួយផ្សេងពីនេះ គឺជាការគេចវេះពីគោលបំណងនៃវិធាន១០៤.៤.ក នេះ។

១២- ភាពចាំបាច់សម្រាប់បណ្តឹងសាទុក្ខភ្លាមៗនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ កាន់តែក្លាយទៅជាការពិតជាក់ស្តែង នៅពេលមានការពិចារណាថា ជម្រើសដែលមានតែមួយគត់នៅក្រោមវិធានផ្ទៃក្នុង គឺ

---

[28] **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៣ ធ្នូ ២០១១, កថាខណ្ឌ១៥។ សូមមើល ឯកសារ E51/15/1/2.1 យោបល់ជំទាស់របស់ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinge លើ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន៨៩ នៃវិធានផ្ទៃក្នុង(គោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ និងការអនុគ្រោះទោស)" ថ្ងៃទី២០ មិនា ឆ្នាំ២០១២ (បដិសេធ "អំណះអំណាងមិនច្បាស់លាស់ដែលថា យុត្តាធិការរបស់អង្គជំនុំជម្រះនេះលើបណ្តឹងសាទុក្ខភ្លាមៗត្រូវបានកំហិតតឹងរ៉ឹងត្រឹមកាលៈទេសៈចង្អៀត ដូចមានរៀបរាប់ក្នុងវិធាន១០៤ (៤)។

[29] **E138/1/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល*, កថាខណ្ឌ១៥។

[30] **E138/1/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល*, កថាខណ្ឌ១៥។

[31] **E138/1/7** *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល*, កថាខណ្ឌ១៥។

“បណ្តឹងសាទុក្ខដែលបានធ្វើឡើង ស្របពេលជាមួយបណ្តឹងសាទុក្ខនឹងសាលក្រមលើអង្គសេចក្តី”[32]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ។ អង្គជំនុំជម្រះបានពិចារណាអំពីភាពស្មុគស្មាញផ្លូវច្បាប់នៃការផ្អាកកិច្ចដំណើរការនីតិវិធី ដែលអាចរារាំង “ដល់ការចេញសាលក្រមលើអង្គសេចក្តី”[33]។ សនិទានភាពរបស់អង្គជំនុំជម្រះអនុវត្តដោយស្មើភាពគ្នា ចំពោះការបញ្ចប់កិច្ចដំណើរការនីតិវិធីឲ្យមានប្រសិទ្ធភាព ចំពោះអង្គហេតុចោទប្រកាន់ និងបទចោទជាក់លាក់ សូម្បីតែនៅពេលបទចោទនោះនៅបន្តទៅមុខទៀតក៏ដោយ។

១៣- ចំពោះការពិចារណាអំពីអង្គហេតុ និងការអនុវត្តជាក់ស្តែងមានចែងខាងក្រោមនេះ សេចក្តីសម្រេចដែលរងការជំទាស់នេះរារាំងដល់ការវិនិច្ឆ័យសេចក្តីលើ បទចោទនានាពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលគេមិនបានដាក់បញ្ចូន។ បន្ថែមលើនេះ នៅពេលចេញសាលក្រមលើសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញានឹងពុំមានដំណោះស្រាយប្រសិទ្ធភាពណាមួយ នៅចំពោះមុខអង្គជំនុំជម្រះឡើយ ចំពោះកំហុសឆ្គងនានាដែលបានចោទប្រកាន់ ដោយសារពុំមានយន្តការតាមផ្លូវច្បាប់ណាមួយ និងមិនអាចដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលបានច្រានចោលក្នុងបណ្តឹងសាទុក្ខ។ សរុបមក មិនមានឱកាសដើម្បីប្តឹងសាទុក្ខចំពោះបញ្ហានេះ នៅក្រោយពេលចេញសាលក្រមស្ថាពរលើអង្គសេចក្តីឡើយ[34]។

សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា “ការបកស្រាយសមហេតុផល” នូវវិធាន១០៤ នៃវិធានផ្ទៃក្នុង ត្រូវតែអនុញ្ញាតឲ្យមានសិទ្ធិក្នុងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខដោយប្រសិទ្ធភាព។ នៅក្នុងករណីជាច្រើន សិទ្ធិនេះអាចនឹងត្រូវបានធានាដោយការធ្វើបណ្តឹងសាទុក្ខនៅក្រោយពេលចេញសាលក្រម ក៏ប៉ុន្តែនៅក្នុងករណីមួយចំនួន រួមក្នុងពេលបច្ចុប្បន្ននេះផង សិទ្ធិនោះត្រូវបានការពារ។ គោលការណ៍នេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមូលដ្ឋានដទៃទៀត ដែលគេអនុញ្ញាតសម្រាប់ឲ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ ស្របទៅតាមវិធាន១០៤.៤។ ការខូចខាតនានាដោយសារការបាត់បង់សេរីភាព អនុលោមតាមវិធាន១០៤.៤.ខ និងការខូចខាតដែលជាប់ពាក់ព័ន្ធទៅនឹងសុវត្ថិភាព និងអត្តសញ្ញាណរបស់សាក្សីនានា នៅក្រោមវិធាន១០៤.៤.គ មិនអាចដោះស្រាយបានប្រកបដោយប្រសិទ្ធិភាពទេ បន្ទាប់ពីមាន

---

[32] វិធាន១០៤ នៃវិធានផ្ទៃក្នុង។

[33] **E138/1/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ១៣ ធ្នូ ២០១១, កថាខណ្ឌ១៥។

[34] **E95/8/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ១៩ មីនា ២០១២, កថាខណ្ឌទី៩ (“សិទ្ធិធ្វើបណ្តឹងសាទុក្ខ ដែលមានចែងក្នុងវិធាន១០៤.៤.ក នៃវិធានផ្ទៃក្នុង ធានាថា បណ្តឹងសាទុក្ខមួយអាចកើតមាននៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយពុំបានចេញសាលក្រម និងពុំមានឱកាសធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ”)។

សាលក្រមនោះ ពីព្រោះគេមិនអាចជួសជុលការខូចខាតនោះបានឡើយ។ អាស្រ័យហេតុនេះ បណ្តឹងសាទុក្ខភ្លាមៗត្រូវតែធ្វើឡើង។ ក្នុងន័យនេះ ការពិតគឺមានដូចគ្នា។

## ខ. លទ្ធភាពធ្វើសវនាការនានានៅពេលអនាគតនៃសំណុំរឿង00២ គឺភាគច្រើនបំផុត ឋិតនៅឆ្ងាយ មិនអាចមើលឃើញ

១៥- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា វាជាការសមហេតុផលដែលត្រូវធ្វើការសន្និដ្ឋានថា សវនាការ នាពេលអនាគតនៅក្នុងសំណុំរឿងលេខ00២ នឹងមិនមានកើតឡើងឡើយ ឬមួយក៏លទ្ធភាព គឺឋិតនៅឆ្ងាយមើលមិនឃើញ។ មេធាវីការពារក្តីរបស់ អៀង សារី[35] នួន ជា[36] និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[37] ធ្លាប់បានបញ្ចេញនូវទស្សនៈនេះរួចហើយ។ ដោយលទ្ធភាពធ្វើសវនាការ នាពេលអនាគតឋិតនៅឆ្ងាយ នោះនឹងពុំមានឱកាស ដើម្បីលើកអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនជាប់ចោទដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនានា ដែលមិនបានដាក់បញ្ចូលឡើយ។ សហព្រះរាជអាជ្ញាមានការសោកស្តាយយ៉ាងខ្លាំងចំពោះអង្គហេតុនេះ ហើយគួរតែបានឃើញតុលាការធ្វើការជំនុំជម្រះក្តីលើជនជាប់ចោទពីឧក្រិដ្ឋកម្មទាំងអស់របស់គាត់ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ទោះជាយ៉ាងណាក៏ដោយ តាមពិតនៅក្នុងតុលាការ សហព្រះរាជអាជ្ញាត្រូវតែប្រតិបត្តិតាមការពិតជាក់ស្តែងដែលគេជួប (រួមទាំងអំណះអំណាងដូចមានចែងនៅខាងក្រោម) ជាជាង ទៅតាមលក្ខណៈគំនិតដែលខ្លួនចង់បាន។

១៦- ជនជាប់ចោទចំនួនបីនាក់ ដែលនៅសល់ក្នុងសំណុំរឿងលេខ00២ គឺទាំងអស់គ្នាសុទ្ធតែមានអាយុច្រើន។ អៀង សារី ៨៧ឆ្នាំ។ នួន ជា ៨៦ឆ្នាំ។ ខៀវ សំផន ៨១ឆ្នាំ។ អាយុកាលមធ្យមរបស់មនុស្ស

---

[35] Julia Wallace, "យុត្តិធម៌នៅមុខក្រចកសេះ ក្នុងតុលាការខ្មែរក្រហម", ៣0 កញ្ញា ២0១២, http://www.aljazeera.com/indepth/features/2012/09/201292514155691 7463.html (សម្រង់សេចក្តីបានភ្ជាប់ទៅលោក Karnavas៖ "ជនណាក៏ដោយដែលទទួលបានពិសោធន៍នៅក្នុងសំណុំរឿងដ៏ធំសម្បើមនេះ ខណៈដែលដាក់កត្តាលើភ័ស្តុតាងដែលពាក់ព័ន្ធនឹងអាយុរបស់ជនជាប់ចោទ មុខជានឹងអាចប្រមើលមើលឃើញរួចជាស្រេចថា ភាពលើសគ្នានៃការជំនុំជម្រះក្តីដែល នៅសល់ ... គឺសូន្យ។ គំនិតរវើរវាយ")។

[36] ពង្រាងប្រតិចារឹក, ២២ តុលា ២0១២ ត្រង់ទំព័រ៨ បន្ទាត់ ១៧-២១ **[ភាសាខ្មែរត្រង់ទំព័រ ៧ បន្ទាត់២៥ និងត្រង់ទំព័រ៨ បន្ទាត់ ១-៤]** (លោក អេនគ្រូ អ៊ីនូហ្ស៊ី៖ "... ខ្ញុំគិតថា យើងគប្បីតែពិនិត្យមើលសញ្ញាណមួយដែលថា ថាតើវាអាចនឹងមានការជំនុំជម្រះរឿងក្តីថ្មីមួយទៀតដែរ រឿងដែលយើងកំពុងពិភាក្សា។ ដូច្នេះតែពីរឿងក្តី00២/0១ តែប៉ុណ្ណោះ។ ដូច្នេះ យើងយល់ស្របគ្នាលើនេះហើយ")។

[37] **E124/8** សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យពិចារណាឡើងវិញនូវខ្លឹមសារក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលេខ E124, ១៨ តុលា ២0១១, ត្រង់កថាខណ្ឌទី១ ("... យើងជឿថា ការជំនុំជម្រះក្តីនេះអាចជាការជំនុំជម្រះក្តីចុងក្រោយមួយ")។

ប្រុសនៅក្នុងប្រទេសកម្ពុជា គឺប្រមាណជា៥៧ឆ្នាំ[38]។ អង្គហេតុ ទាំងនេះ គឺនិយាយតែពីបរិមាណ។ ដូចដែលតុលាការបានឃើញស្រាប់ ទាក់ទងនឹង អៀង ធីរិទ្ធ គឺមិនគ្រាន់តែជាលទ្ធភាពនៃមរណភាពប៉ុណ្ណោះទេ ក៏ប៉ុន្តែជាសេចក្តីព្រួយបារម្ភទាក់ទងនឹងសុខភាពដែលកាន់តែធ្ងន់ធ្ងរទៅតាមអាយុដែលកាន់តែច្រើន អាចធ្វើឱ្យតុលាការនេះ បាត់ឱកាសថែមទៀត ក្នុងការជំនុំជម្រះជនជាប់ចោទនេះ។ តាមការពិត អៀង សារី និង នួន ជា បានអះអាងដដែលៗថា សេចក្តីព្រួយបារម្ភទាំងនេះ គឺប៉ះពាល់ដល់លទ្ធភាពខាងផ្លូវកាយរបស់ពួកគាត់ ហើយក្នុងករណីខ្លះ ប៉ះពាល់ដល់សតិបញ្ញាក្នុងការចូលរួមសវនាការ នៅក្នុងកម្រិតខុសៗគ្នា[39]។

១៧- ភវនីយភាពនៃការផ្អាកកិច្ចដំណើរការនីតិវិធីដោយសារទាក់ទងនឹងបញ្ហាសុខភាព ដែលប្រឆាំងនឹងជនជាប់ចោទដែលនៅសល់ម្នាក់ ឬច្រើននាក់ ដែលអាចធ្វើឱ្យរាំងស្ទះដល់សវនាការជាបន្តបន្ទាប់ទៅទៀត គឺមានកម្រិតកាន់តែខ្ពស់ឡើង នៅពេលគេពិចារណាថា ពេលវេលាបន្ថែមនឹងត្រូវផុតកំណត់ នៅមុនពេលបញ្ចប់សវនាការលើសំណុំរឿងលេខ០០២/០១។ ការចេញសាលក្រម និងភាពទំនងជាមានការពន្យារពេលជាកង់ៗ ដោយសារមូលហេតុធំៗមួយចំនួនទៀត សូម្បីតែសំណុំរឿងលេខ០០២/០២ មានដំណើរការទៅមុខក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ដោយខ្លួនឯងថា "ពិតជាមានការព្រួយបារម្ភមួយថាតើជនជាប់ចោទនឹងអាចចូលរួមទាំងផ្លូវកាយ និងបញ្ញាស្មារតីក្នុងការជំនុំជម្រះដែលមានរយៈពេលវែងយ៉ាងណាដែរ"[40]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលថ្មីៗ

---

[38] អង្គការសុខភាពពិភពលោក, តួលេខសម្រាប់ឆ្នាំ២០០៩, ដែលអាចបើកមើលបាននៅអាសយដ្ឋាន : http://www.who.int/countries/khm/en/។

[39] *សូមអាន ឧទាហរណ៍ដូចជា* **E1/125.1** ប្រតិចារិកនៃដំណើរការនីតិវិធីសវនាការ, ២១ កញ្ញា ២០១២ (ដែលពិភាក្សាអំពីស្ថានភាពសុខភាពរបស់ អៀង សារី)។ **E1/120.1** ប្រតិចារិកនៃដំណើរការនីតិវិធីសវនាការ, ៣ កញ្ញា ២០១២, កថាខណ្ឌទី ២, ៥១ (ដែលកត់សម្គាល់ថា សំណើរបស់ អៀង សារី និង នួន ជា ដែលសុំឱ្យអនុវត្តដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងមក ដោយសារមូលហេតុព្រួយបារម្ភអំពី សុខភាព)។ **E1/121.1** ប្រតិចារិកនៃដំណើរការនីតិវិធីសវនាការ, ៤ កញ្ញា ២០១២, ទំព័រ២ (ដែលកត់សម្គាល់ថា សំណើរបស់ អៀង សារី ដែលសុំឱ្យអនុវត្តដំណើរការនីតិវិធីចាប់តាំងពីការដាក់នៅក្នុងបន្ទប់ឃុំឃាំងមក ព្រោះដោយសារមានការព្រួយបារម្ភអំពីបញ្ហាសុខភាព)។ **E1/122.1** ប្រតិចារិកនៃដំណើរការនីតិវិធីសវនាការ, ៥ កញ្ញា ២០១២, កថាខណ្ឌទី២,៥៣ (ដែលកត់សម្គាល់ថា សំណើរបស់ អៀង សារី និង នួន ជា ដែលសុំឱ្យអនុវត្តដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងមក ព្រោះដោយសារមូលហេតុព្រួយបារម្ភអំពីសុខភាព)។ **E1/123.1** ប្រតិចារិកនៃដំណើរការនីតិវិធីសវនាការ, ៦ កញ្ញា ២០១២, កថាខណ្ឌទី២ ,៦៨ (ដូចគ្នាដដែល)។

[40] **E124/7** សេចក្តីសម្រេចលើសំណើររបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យពិនិត្យឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងសំណើសុំពាក់ពន្ធនានា និងឧបសម្ព័ន្ធ, ១៨ តុលា ២០១១, កថាខណ្ឌទី១១។

ដើម្បីកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការប្រចាំសប្តាហ៍ គឺពីបួនថ្ងៃ មកបីថ្ងៃ បានធ្វើឱ្យកង្វល់នេះកាន់តែធ្ងន់ធ្ងរឡើង[41]។

១៨- ពិតមែនហើយ មានបញ្ហាជាច្រើនដែលមិនទាន់បានដោះស្រាយនៅឡើយ ថាតើនៅពេលណា និងតាមរបៀបណា ដែលសំណុំរឿងលេខ០០២/០២ធំដូចនេះ អាចនឹងដំណើរការទៅមុខបាន។ យ៉ាងហោចណាស់ ត្រូវមានសក្តានុភាពដែលសេចក្តីសម្រេចលើ*បណ្តឹងសាទុក្ខ* នៅក្នុងសំណុំរឿងលេខ០០២/០១ ត្រូវតែចេញឱ្យបានមុនពេលសំណុំរឿងលេខ០០២/០២ដែលជាសម្មតិកម្មនោះ អាចនឹងត្រូវបានដំណើរការ។ បញ្ហានានាខាងច្បាប់ និងខាងការអនុវត្ត នៅមិនទាន់បានដោះស្រាយនៅឡើយទេ រួមទាំងកង្វល់ផ្សេងៗដែលទាក់ទងទៅនឹង ថាតើដោះស្រាយអំពីការជូនដំណឹងអង្គហេតុ ដែលបានជំនុំជម្រះរួច និងអាជ្ញាអស់ជំនុំយ៉ាងដូចម្តេច ចំពោះការដាក់ឯកសារណាមួយក្នុងសំណុំរឿងលេខ០០២/០១[42]។ សហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងពីមុនៗនូវកង្វល់ទាំងនេះ ជូនដល់អង្គជំនុំជម្រះសាលាដំបូងរួចហើយ ដោយបានធ្វើការបញ្ជាក់ថា ខ្លួនមិនពិចារណាទេ "ថាបណ្តឹងសាទុក្ខណាមួយចំពោះសាលក្រម

[41] សេចក្តីប្រកាសព័ត៌មាន, "អង្គជំនុំជម្រះសាលាដំបូងកាត់បន្ថយចំនួនថ្ងៃសវនាការ នៅក្នុងសំណុំរឿងលេខ០០២/០១", ២៣ តុលា ២០១២ និងអាចរកមើលបាននៅគេហទំព័រ៖http://www.eccc.gov.kh/en/articles/trial-chamber-reduces-number-weekly-hearing-days-case-0021.

[42] **E124/2** សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពី "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង", ថ្ងៃទី៣ តុលា ២០១១, កថាខណ្ឌទី២៦-២៨។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថាវាអាចមានឧបសគ្គតាមផ្លូវច្បាប់ក្នុងការប្រើប្រាស់មូលដ្ឋានអង្គហេតុ និងអង្គច្បាប់ដែលបានមកពីសវនាការទីមួយ នៅក្នុងសវនាការជាបន្តបន្ទាប់មកទៀតនោះ។ វិធីសាស្ត្រនានា ដែលតាមរយៈវិធីសាស្ត្រទាំងនោះគេអាចនឹងធ្វើសវនាការបន្តបន្ទាប់មកទៀតបានយ៉ាងឆាប់រហ័ស គឺជាការជូនដំណឹងតាមផ្លូវតុលាការនៃអង្គហេតុនានាដែលបានវិនិច្ឆ័យរួចហើយ, ហើយនិង*អាជ្ញាអស់ជំនុំ (res judicata)*។ យ៉ាងណាក៏ដោយ ក៏គោលការណ៍ទាំងនេះអាចនឹងត្រូវបានរារាំងតាមផ្លូវច្បាប់ដោយអាស្រ័យលើសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខក្នុងដំណាក់កាលសវនាការដំបូង។ យុត្តិសាស្ត្រអន្តរជាតិបានបញ្ជាក់ ថា លក្ខខណ្ឌចាំបាច់សម្រាប់ "ការជូនដំណឹងតាមផ្លូវតុលាការនៃអង្គហេតុនានាដែលបានវិនិច្ឆ័យរួចហើយ" គឺថាអង្គហេតុនោះ "ត្រូវបាន វិនិច្ឆ័យដោយពិតប្រាកដ" ដែលទិដ្ឋភាពមួយក្នុងចំណោមនោះគឺថាអង្គហេតុពាក់ព័ន្ធដែលបានមកពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលា ដំបូង៖ ទី១) មិនត្រូវបានប្តឹងសាទុក្ខ ឬទី២) មិនទាន់ត្រូវបានសម្រេចជាចុងក្រោយលើបណ្តឹងសាទុក្ខ។ ដូចគ្នានេះដែរ ការអនុវត្តគោលការណ៍ *អាជ្ញាអស់ជំនុំ (res judicata)* តម្រូវថា បញ្ហានានាតាមផ្លូវច្បាប់ត្រូវបានប្តឹងរួចរាល់ទាំងស្រុងអស់ហើយ។ ដូច្នេះ មានបញ្ហាមួយចំនួនដែល ទាក់ទងទៅនឹងលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទាញយកផលប្រយោជន៍ពីយន្តការទាំងនេះ នៅមុនពេលចេញសេចក្តីសម្រេច លើបណ្តឹងសាទុក្ខ។ បញ្ហាសក្តានុពលតាមផ្លូវច្បាប់ដែលអាចមានផលប៉ះពាល់ទៅលើសវនាការទីពីរ រួមមាន ការលើកលែងទោស និងការ អនុគ្រោះទោស, និយមន័យនៃឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ, ហើយនិងភាពអាចទទួលយកបាន និងការប្រើប្រាស់ដ៏ ត្រឹមត្រូវនៃភ័ស្តុតាង។ ការស្មុគស្មាញបន្ថែមទៀតនៅក្នុងការប្រើប្រាស់អង្គហេតុដែលបានវិនិច្ឆ័យរួចហើយនោះ គឺថាអង្គជំនុំជម្រះសាលាដំបូង ខ្លួនឯងធ្លាប់បានថ្លែងថា"មិនមាននូវមូលដ្ឋានផ្លូវច្បាប់ឡើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ឱ្យអង្គជំនុំជម្រះ ធ្វើការកត់សម្គាល់នូវអង្គហេតុដែលបានវិនិច្ឆ័យរួចហើយ ឬអង្គហេតុនៃការដឹងឮជាទូទៅយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក នោះទេ"។ **E69/1** សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ០០១ ដែលបានវិនិច្ឆ័យរួចហើយ និង អង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ០០២, ៤ មេសា ២០១១, ទំព័រទី៣។

ដំបូងនេះ រារាំងមិនឲ្យមានការបន្តសវនាការបន្តបន្ទាប់ទៀត ក្នុងសំណុំរឿងលេខ០០២/០១”[43]។ ទោះជាយ៉ាងណាក៏ដោយ យ៉ាងហោចណាស់ ការស្រាវជ្រាវពេញលេញអំពីបញ្ហាទាំងនេះ អាចជាការចាំបាច់ខានមិនបាន។ ដំណើរការដោយខ្លួនឯងនោះ នឹងត្រូវចំណាយពេលដោយចៀសពុំរួចឡើយ។

១៩- វិធាន២១ បានចែងអំពីការណែនាំសម្រាប់ធ្វើការបកស្រាយបន្ថែមទៀតដែលគាំទ្រដល់ភាពអាចទទួលយកបានចំពោះបណ្តឹងសាទុក្ខៗនេះ។ វិធាន២១ បានបង្គាប់ថា វិធានផ្ទៃក្នុង “ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព”។ ទោះបីជាពុំមានសិទ្ធិទូទៅនៅក្នុងបណ្តឹងបន្ទាន់បង្ខំ[44]ក៏ដោយ ក៏ភាសាយ៉ាងសាមញ្ញនៃវិធាន២១បានបង្កើតឡើងថា សិទ្ធិរបស់ជនរងគ្រោះ និងផលប្រយោជន៍នៃសច្ចភាព និងតម្លាភាពខាងផ្លូវច្បាប់ គឺឋិតនៅក្នុងចំណោមផលប្រយោជន៍ទាំងឡាយដែលមានឧត្តមភាពនៅក្នុងការបកស្រាយវិធានផ្ទៃក្នុងនេះ។ ការដែលអនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខភ្លាមៗក្នុងបញ្ហានេះ អាចមិនមានផលប៉ះពាល់ទៅលើសិទ្ធិរបស់ភាគីណាមួយឡើយ ប៉ុន្តែអាចការពារដល់សិទ្ធិរបស់ជនរងគ្រោះដែលកំពុងស្វែងរកឲ្យមានការចោទប្រកាន់ទៅលើពួកគាត់អំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត។ វាអាចជំរុញផងដែរឲ្យមានសច្ចភាព និងតម្លាភាពខាងផ្លូវច្បាប់សម្រាប់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងសុពលភាព និងសម្អាងហេតុក្នុងនោះ ការបំបែកកិច្ចដំណើរការនីតិវិធី និងថាតើវាមានការរំពឹងទុកពិតប្រាកដយ៉ាងណាដែលថាតុលាការនេះ នឹងវិនិច្ឆ័យលើការចោទប្រកាន់នានាដែលពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលមិនបានដាក់បញ្ចូល នៅពេលអនាគតដែលអាចដឹងជាមុននោះ។

## គ. បណ្តឹងសាទុក្ខនេះបានដាក់នៅក្នុងពេលកំណត់ដែលអាចដាក់បាន

២០- បណ្តឹងសាទុក្ខនេះ ត្រូវបានដាក់ក្នុងពេលកំណត់ដែលមានចែងនៅក្នុងវិធាន១០៧.១ គឺនៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីមានសេចក្តីសម្រេចដែលរងការជំទាស់នេះ។ ខណៈដែលមានដីកាបំបែកកិច្ចដំណើរការនីតិវិធីពីដំបូង ត្រូវបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទុកលទ្ធភាពចំហរជាក់ច្បាស់ ក្នុងការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀត នៅក្នុងសវនាការនេះ គឺ

---

[43] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ថ្ងៃទី១៨ តុលា ២០១១, កថាខណ្ឌទី៧, ៨ និង កំណត់សម្គាល់ជើងទំព័រលេខ១០។

[44] **E154/1/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់, ថ្ងៃទី២៥ មេសា ២០១២។

មាននៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី និងនៅក្នុងសេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញ។ ដូច្នេះ បញ្ហានៃទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀតនេះ គឺនៅបើកចំហរនៅឡើយ ហើយសហព្រះរាជអាជ្ញាបានទប់មិនប្តឹងសាទុក្ខទៅនឹងដីកាសម្រេចដំបូង រហូតទាល់តែវិសាលភាពនៃការបំបែកត្រូវបានកំណត់ជាក់ច្បាស់ចុងក្រោយ។ គឺបន្ទាប់ពីមានសេចក្តីសម្រេចដែលរងការជំទាស់នេះដែលការបំបែកនេះមានអានុភាពពេញលេញ ដោយបានបញ្ចប់នូវកិច្ចដំណើរការនីតិវិធីដោយប្រសិទ្ធភាពទាក់ទងទៅនឹងស-២១ និងទីតាំងឧក្រិដ្ឋកម្មក្នុងស្រុក ១២។

## IV. សេចក្តីសន្និដ្ឋានគាំទ្របណ្តឹងសាទុក្ខ

### ក. អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ និង/ឬមានកំហុសនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវចំពោះការបំបែកបទចោទ

២១- សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ ឬមានកំហុសនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានអនុវត្តបទដ្ឋានគតិយុត្តត្រឹមត្រូវចំពោះការបំបែកបទចោទ ក្នុងការបដិសេធទីតាំងឧក្រិដ្ឋកម្មក្នុងស្រុក១២ និងមន្ទីរស-២១។ ដូចដែលបានបញ្ជាក់ជូនខាងលើ សេចក្តីសម្រេចនោះគឺជាសេចក្តីសម្រេចដែលរងការជំទាស់ បានកំណត់ជាក់លាក់នូវវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីផលវិបាកផ្នែកច្បាប់នៃសេចក្តីសម្រេចនៅក្នុងអនុស្សរណៈមួយ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ដោយបានបញ្ជាក់ថា៖ "ពុំមានការពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ឲ្យលើសពីនេះទៀតឡើយ[45]។ ដូច្នេះ សេចក្តីសម្រេចដែលរងការជំទាស់ត្រូវត្រួតពិនិត្យដោយច្បាប់ជាធរមានស្តីពីការបំបែកបទចោទ ពីព្រោះវាជាផ្នែកមិនអាចផ្តាច់បាននៃការបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង។

២២- ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជូនខាងលើ សេចក្តីសម្រេចដែលរងការជំទាស់ត្រូវបានធ្វើឡើងតាមរយៈការពិចារណាអំពីកត្តាខាងក្រោមនេះ៖ មានហានិភ័យដែលធ្វើឲ្យការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ អូសបន្លាយពេលយូរ ថាតើទីតាំងឧក្រិដ្ឋកម្មទាំងនេះ "ជាប់ពាក់ព័ន្ធជិតស្និទ្ធ

---

[45] ឯកសារ **E223/2** អនុស្សរណៈមានចំណងជើងថា "សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223) ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ៣។

ទៅនឹងការចោទប្រកាន់ក្នុងអង្គហេតុក្នុងសំណុំរឿង០០២/០១ ឬយ៉ាងណា និងថាតើការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀត "សមស្របតាមលំដាប់លំដោយត្រឹមត្រូវនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២ ដូចដែលបានរៀបរាប់ក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី ឬយ៉ាងណា"[46]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះដឹងអំពី "ការពន្យារពេល" កាលពីមុន ដូច្នេះមិនបាន "ពិចារណាអំពីការពង្រីកវិសាលភាពទូលំទូលាយនៃការជំនុំជម្រះចំពោះការអនុវត្តឆន្ទានុសិទ្ធិក្នុងការរៀបចំកិច្ចប្រជុំសវនាការប្រកបដោយទេពកោសល្យ"[47]។ សហព្រះរាជអាជ្ញានឹងលើកឡើងនូវកំហុសនានា ទាក់ទិននឹងការពិចារណាទាំងនេះនៅក្នុងផ្នែក **(គ)** ខាងក្រោម។

២៣- នៅក្នុងផ្នែកនេះ សហព្រះរាជអាជ្ញានឹងបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកច្បាប់ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងដូចម្ដេចដោយអនុលោមតាមវិធាន៨៩ស្ទួនពីរ ដោយខកខានមិនពិចារណាថាតើបទចោទដែលដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ គ្របដណ្ដប់ទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬយ៉ាងណា។ ការមិនដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មនានាដែលសហព្រះរាជអាជ្ញាបានស្នើឡើងនោះ ធ្វើឲ្យបាត់បង់នូវបទចោទនានា ដែលតាមពិត មិនគ្របដណ្ដប់ទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ សហព្រះរាជអាជ្ញា និងគោលដៅនៃការផ្សះផ្សាជាតិ និងកំណត់ប្រវត្តិសាស្ត្រត្រឹមត្រូវ។ ដោយពិចារណាទៅលើទិដ្ឋភាពនៃកំហុសផ្នែកច្បាប់ ការសម្រេចមិនត្រឹមត្រូវលើច្បាប់ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង បាននាំមកនូវសេចក្ដីសម្រេចមួយផ្ទុយទៅនឹងការអនុវត្តច្បាប់ត្រឹមត្រូវ។ ដោយពិចារណាទៅលើទិដ្ឋភាពនៃកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិ ការវាយតម្លៃដោយខុសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពត្រឹមត្រូវ និងផលប៉ះពាល់ដល់វិសាលភាពដែលបានស្នើសុំ ផ្ដល់នូវដំណោះស្រាយមួយមិនអាចជួសជុលបាន ចំពោះសហព្រះរាជអាជ្ញា និងផលប្រយោជន៍ដែលសហព្រះរាជអាជ្ញាបានដាក់ជូន។

### *i. ការពិនិត្យឡើងវិញចំពោះការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង*

២៤- អង្គជំនុំជម្រះសាលាដំបូងបានពណ៌នាសេចក្ដីសម្រេចដែលរងការជំទាស់ថា ជាការប្រើប្រាស់ "ឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រងសវនាការ"របស់ខ្លួន[48]។ សហព្រះរាជអាជ្ញាយល់ព្រមថា ឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រងសវនាការជាធម្មតារបស់អង្គជំនុំជម្រះនោះ នឹងមិនត្រូវបានរំខានដោយការប្ដឹងសាទុក្ខនោះឡើយ

---

[46] ឯកសារ **E163/5** សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

[47] ឯកសារ **E163/5** ដូចយោងខាងលើ កថាខណ្ឌ ២។

[48] E163/5 ដូចយោងខាងលើ កថាខណ្ឌ ២។

ដោយសហព្រះរាជអាជ្ញាទទួលស្គាល់នូវ "ការក្តាប់ជាប់យ៉ាងលម្អិតរបស់អង្គជំនុំជម្រះសាលាដំបូង នូវការប្រព្រឹត្តិទៅជាប្រចាំថ្ងៃរបស់ភាគីនានា ក៏ដូចជាតម្រូវការជាក់ស្តែងនៃសំណុំរឿង"[49]។ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី (ICTY) មានកំណត់យ៉ាងច្បាស់ថា ការគោរពត្រូវបានធ្វើឡើងតាមរយៈបណ្តឹងសាទុក្ខចំពោះ "ប្រភេទនៃសេចក្តីសម្រេចនានាក្នុងគោលបំណងឲ្យមានការគ្រប់គ្រងសវនាការ ប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស"[50]។

២៥- ក៏ប៉ុន្តែការគោរពចំពោះសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនេះ មិនមែនជាការគោរពយ៉ាងដាច់ខាតនោះទេ។ នេះមិនមែនជាការតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការពិនិត្យមើលឡើងវិញថាតើសកម្មភាពដែលបានធ្វើកន្លងមក ស្ថិតនៅក្នុងដែនកំណត់នៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ឬយ៉ាងណានោះទេ ហើយក៏មិនមែនពិនិត្យមើលថាសកម្មភាពនេះធ្វើឡើងដោយពឹងផ្អែកទៅលើអង្គហេតុ ឬអង្គច្បាប់ដែលមិនត្រឹមត្រូវនោះដែរ។ នៅក្នុងការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលពាក់ព័ន្ធទៅនឹងបញ្ហាឆន្ទានុសិទ្ធិ ក្នុងករណីដែល "សេចក្តីសម្រេចនោះត្រូវបានរកឃើញថា (១)ពឹងផ្អែកទៅលើការបកស្រាយដោយមិនត្រឹមត្រូវនូវច្បាប់ជាធរមាន (២)ពឹងផ្អែកទៅលើការសន្និដ្ឋានដោយមិនត្រឹមត្រូវយ៉ាងជាក់ស្តែងនូវអង្គហេតុ ឬ(៣) មានភាពមិនយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលជាការបង្ហាញពីការរំលោភបំពានទៅលើឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូង"[51]។ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក ក៏បានអនុវត្តតាមយុត្តាធិការរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការមិនអចិន្ត្រៃយ៍មួយនេះផងដែរ លើបញ្ហានេះ[52]។

---

[49] រដ្ឋអាជ្ញា តទល់នឹង *Milan Milutinovic និងអ្នកដទៃ* សំណុំរឿងលេខ IT-05-87-AR73.1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ ប្រឆាំងសេចក្តីសម្រេចលើកទីពីរ ដែលរារាំងរដ្ឋអាជ្ញាមិនឲ្យបន្ថែមលោកឧត្តមសេនីយ៍ Wesley Clark ទៅក្នុងបញ្ជីសាក្សី ៦៥ ស្ទួនបីរបស់ខ្លួន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY) ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ៨។

[50] ដូចយោងខាងលើ កថាខណ្ឌ ៨។

[51] *រដ្ឋអាជ្ញា តទល់នឹង* Jadranko Prlić *និងអ្នកដទៃ.*, សំណុំរឿងលេខ IT-04-74 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើររបស់ Slobodan Praljak សុំឲ្យធ្វើការដោះលែងជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY) ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ កថាខណ្ឌ៥។

[52] ឯកសារលេខ **D164/4/13** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ERN: 00402746-62 ត្រង់កថាខណ្ឌ ២២ ដល់២៧ (ដកស្រង់រឿងក្តី *Milosevic តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ IT-02-S4-AR73.7 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំប្តឹងទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការតែងតាំងមេធាវីការពារក្តី" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៤ ត្រង់កថាខណ្ឌ ៩ ដល់១០, **D140/9/5** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកា

២៦- គោលការណ៍ទាំងនេះអនុវត្តផងដែរចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងឆន្ទានុសិទ្ធិ ក្នុងការគ្រប់គ្រងសវនាការ។ បណ្តាឧទាហរណ៍នានានៃ "សេចក្តីសម្រេចបែបនេះ" ដែលត្រូវបានពិនិត្យមើលដោយអង្គជំនុំជម្រះតុលាការកំពូល រួមមានសេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន[53] និងសេចក្តីសម្រេចកំណត់ចំនួនសាក្សីដែលត្រូវកោះហៅក្នុងរឿងក្តី[54]។

២៧- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី *Haradinaj* បានទទួលនូវបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា ដែលបានប្តឹងពីការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កំណត់កាលបរិច្ឆេទសម្រាប់សាក្សី[55]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសវនាការ ដូចជាសេចក្តីសម្រេចកំណត់ពេលវេលាដែលត្រូវផ្តល់ឲ្យភាគី ក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន ក៏ដូចជាការស្នើសុំពេលវេលាបន្ថែមក្នុងការបង្ហាញភស្តុតាង គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្តែងនូវការគោរពរបស់ខ្លួន[56]។ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានសង្កត់ធ្ងន់ផងដែរ ទៅលើសារៈសំខាន់នៃការវាយតម្លៃលើសេចក្តីសម្រេច

---

សម្រេចរបស់ ក.ស.ច.ស ដែលបដិសេធសំណើរបស់គាត់សុំតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញ ទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញ ដែលបានដាក់ជូនដោយលោកស្រី Ewa TABEAU និងលោក ថឺ ឃាម ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ១៥ ដល់ ១៧, **D356/2/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ ត្រង់កថាខណ្ឌ ១៦ ដល់ ១៨។

[53] *រដ្ឋអាជ្ញា តទល់នឹង Jadranko Prlić និងអ្នកដទៃ*., សំណុំរឿងលេខ IT-04-74 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់ Slobodan Praljak សុំឲ្យធ្វើការដោះលែងជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY) ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ៤។

[54] រដ្ឋអាជ្ញា តទល់នឹង *Milan Milutinovic និងអ្នកដទៃ* សំណុំរឿងលេខ IT-05-87-AR73.1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ ប្រឆាំងសេចក្តីសម្រេចលើកទីពីរ ដែលរារាំងរដ្ឋអាជ្ញាមិនឲ្យបន្ថែមលោកឧត្តមសេនីយ៍ Wesley Clark ទៅក្នុងបញ្ជីសាក្សី ៦៥ ស្ទួនពីររបស់ខ្លួន អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៩,រដ្ឋអាជ្ញា តទល់នឹង *Milan Martic* Case No. IT-95-11-AR73.2 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភស្តុតាងរបស់សាក្សី Milan Babić អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ ២០០៦ ("សេចក្តីសម្រេច *Martic*") កថាខណ្ឌ ៦ និងជើងទំព័រ ៧។

[55] រដ្ឋអាជ្ញា តទល់នឹង *Ramush Haradinaj និងអ្នកដទៃ* សំណុំរឿង IT-04-84-A សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ICTY ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ១៤ ដល់៣៣។

[56] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ១៧។

តាមឆន្ទានុសិទ្ធិ ដោយផ្អែកទៅលើកត្តាដែលពាក់ព័ន្ធទាំងអស់ មិនមែនត្រឹមតែកត្តាពាក់ព័ន្ធមួយចំនួនដែលមិនច្បាស់លាស់នោះទេ[57]។

២៨- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *Haradinaj* បានរកឃើញជាស្ថាពរថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន ព្រោះនៅពេលធ្វើសេចក្តីសម្រេចកំណត់កាលបរិច្ឆេទសម្រាប់សាក្សី អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាឲ្យបានពេញលេញទៅលើកត្តាពាក់ព័ន្ធទាំងឡាយ រួមទាំងគោលដៅជាចម្បងរបស់ការជំនុំជម្រះ។ អង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ "ការយកចិត្តទុកដាក់ដោយមិនត្រឹមត្រូវ" ទៅលើកត្តាខ្លះដែលនៅពេលពិនិត្យដោយត្រួសៗ ឃើញថាត្រឹមត្រូវតាមច្បាប់ (ដូចជាការគោរពការបែងចែកពេលវេលាសម្រាប់ការបង្ហាញនូវភ័ស្តុតាង)[58] ប៉ុន្តែក្នុងកាលៈទេសៈនានា កត្តាទាំងនេះគឺជា "កត្តាអាទិភាពដែលកំណត់មិនត្រឹមត្រូវ"[59]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានរិះគន់ផងដែរដល់ "អង្គជំនុំជម្រះសាលាដំបូងដែលផ្តោតសំខាន់តែទៅលើការគោរពតាមកាលបរិច្ឆេទកំណត់របស់ខ្លួន ជាជាងការជួយដល់រដ្ឋអាជ្ញាក្នុងការជំនះរាល់ឧបសគ្គនានា តាមបែបជំនុំជម្រះប្រកបដោយយុត្តិធម៌ និងពេញលេញ ហើយក៏បានរិះគន់ផងដែរដល់ការផ្តល់អាទិភាពទៅលើការពិចារណាផ្នែកភ័ស្តុភារ ជាជាងការពិចារណាលើខ្លឹមសារ[60]។ ជាលទ្ធផល បើទោះបីជា "ការខិតខំប្រឹងប្រែងទាំងនេះអាចស្ថិតក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការជំនុំជម្រះដែលធ្វើឡើងក្នុងកាលៈទេសៈធម្មតាក៏ដោយ ក៏បរិបទនៃការជំនុំជម្រះមួយនេះគឺឆ្ងាយពីកម្រិតធម្មតា ហើយដែលតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងយកចិត្តទុកដាក់ជាមុនទៅលើការធានាឲ្យមានភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ការនេះទាមទារឲ្យមានភាពបត់បែនពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាបន្ទាប់បន្សំ ក្នុងការកំណត់កាលបរិច្ឆេទសម្រាប់សាក្សី បញ្ហាភ័ស្តុភារក្នុងសវនាការ ព្រមទាំងកាលបរិច្ឆេទកំណត់[61]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ការដែលអង្គជំនុំជម្រះសាលាដំបូងមិនបានគិតគូរឲ្យគ្រប់ជ្រុងជ្រោយចំពោះកត្តាដែលពាក់ព័ន្ធនានា ព្រមទាំងអនុវត្តវិធីសាស្ត្រ "ទម្រង់ការ ជាជាង មុខងារ" របស់ខ្លួននោះ បានធ្វើឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ហើយនឹងអាចនាំឲ្យមានភាពមិនយុត្តិធម៌[62]។

[57] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៣៩។

[58] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៤០។

[59] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៤០។

[60] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៤១, ៤៣ និង៤៦។

[61] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៤៨។

[62] ដដែលដូចខាងលើ ត្រង់កថាខណ្ឌ ៤៩។

២៩- បន្ថែមពីលើនេះទៀត បើទោះបីជាសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិទៅលើការគ្រប់គ្រងសវនាការអាចត្រូវបានពិនិត្យឡើងវិញ ដោយមានការគោរព ប៉ុន្តែប្រកបដោយអត្ថន័យក៏ដោយ ក៏សហព្រះរាជអាជ្ញាបង្ហាញថា សេចក្តីសម្រេចបំបែកបទចោទប្រកាន់ ដែលទោះបីជាពាក់ព័ន្ធចាំបាច់ទៅលើបញ្ហានៃការគ្រប់គ្រងសវនាការក៏ដោយ ក៏សេចក្តីសម្រេចបែបនេះមានសារៈសំខាន់ទូលំទូលាយជាងនេះទៅទៀត។ ឆន្ទានុសិទ្ធិក្នុងការបំបែកកិច្ចដំណើរការនីតិវិធី គឺពាក់ព័ន្ធជាមួយនឹងផលប្រយោជន៍តាមផ្លូវច្បាប់ជាមូលដ្ឋាន ដែលហួសពីបញ្ហានៃការកំណត់កាលបរិច្ឆេទកោះហៅសាក្សី និងបញ្ហានៃកាលបរិច្ឆេទដាក់ឯកសារ។ ដូច្នេះការនេះទាមទារឲ្យមានការពិនិត្យវិនិច្ឆ័យឲ្យបានល្អិតល្អន់ពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល។

៣០- ដូចដែលសហព្រះរាជអាជ្ញានឹងបង្ហាញជូននៅផ្នែកខាងក្រោមនេះ ដោយខកខានមិនបានអនុវត្តគោលការណ៍ច្បាប់ឲ្យបានត្រឹមត្រូវនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដោយមានការយល់ច្រឡំខ្លួនឯងចំពោះការពិចារណាពាក់ព័ន្ធក្នុងការអនុវត្តឆន្ទានុសិទ្ធិ និងបកស្រាយអង្គហេតុខុសដែលនៅចំពោះមុខខ្លួន អង្គជំនុំជម្រះសាលាដំបូងឈានដល់សេចក្តីសម្រេចមួយមិនសមហេតុសមផលទាំងស្រុងដែលមានអានុភាពផ្ទាល់ទៅលើសិទ្ធិជាមូលដ្ឋាន និងផលប្រយោជន៍តាមផ្លូវច្បាប់របស់ភាគី។ ដូចនេះ ជាការសមស្របទាំងស្រុងសម្រាប់អង្គជំនុំជម្រះតុលាការកំពូលកែប្រែសេចក្តីសម្រេចដែលរងការជំទាស់នេះ និងបង្គាប់ឲ្យកែប្រែវិសាលភាពនៃសំណុំរឿង០០២/០១នេះ។

*ii. នៅក្នុងការបំបែកបទចោទត្រូវតែពិចារណាជាចម្បងទៅលើលក្ខខណ្ឌតម្រូវនៃភាពគ្រប់គ្រាន់សមហេតុផល*

៣១- វិធាន៨៩ស្ទួនពីរ ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា “នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ”។ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាននេះ ត្រូវបានកំណត់ដោយលក្ខខណ្ឌតម្រូវដែលថាការបំបែកត្រូវតែស្ថិតនៅក្នុង “ផលប្រយោជន៍យុត្តិធម៌”។ ពុំមានការណែនាំចែងនៅក្នុងវិធាន នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាទាក់ទិននឹងធាតុផ្សំដែលត្រូវយកមកពិចារណាអំពី “ផលប្រយោជន៍យុត្តិធម៌” ក្នុងបរិបទនៃការបំបែកកិច្ចនីតិវិធី។ ដូច្នេះជាការត្រឹមត្រូវត្រូវងាកទៅរកទម្លាប់អនុវត្តជាអន្តរជាតិ អនុលោមតាមមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៣២- វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY ផ្តល់នូវយន្តការសម្រាប់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ដោយផ្ទាល់ ឬដោយប្រយោលឲ្យកាត់បន្ថយចំនួននៃបទចោទដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងកំណត់ចំនួននៃអង្គហេតុចោទប្រកាន់ (ទីតាំងឧក្រិដ្ឋកម្ម និង/ឬហេតុការណ៍) ដែលនឹងត្រូវជំនុំជម្រះ"[63]។ អនុលោមតាមវិធាន ៧៣ ស្ទួន អង្គជំនុំជម្រះអាច៖

> *កាត់បន្ថយចំនួននៃបទចោទដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ និងអាចកំណត់ចំនួននៃទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍ ដែលមាននៅក្នុងការចោទប្រកាន់មួយ ឬច្រើន ទាក់ទិននឹងភស្តុតាងណាដែលអាចត្រូវបានបង្ហាញដោយរដ្ឋអាជ្ញា ដែលគ្របដណ្តប់ទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដោយពិចារណាទៅលើកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមមានបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រភេទ និងលក្ខណៈ ទីតាំងដែលចោទប្រកាន់ថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ទំហំទំហំនៃឧក្រិដ្ឋកម្ម និងជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ*[64]។

៣៣- ទោះបីជាអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានជំទាស់កាលពីលើកមុនរួចហើយ ជាមួយនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ទាក់ទិននឹងតួនាទីរបស់អយ្យការនៅក្នុងដំណើរការនៃការបំបែកកិច្ចដំណើរការនីតិវិធី ដែលផ្អែកមួយផ្នែកទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងពុំបានជំទាស់ឡើយថា នៅពេលដែលការជំនុំជម្រះបន្ថែមទៀតពុំទំនងជាកើតមាននោះ បទចោទនានាគួរតែគ្របដណ្តប់ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល[65]។ ទោះបីជាយ៉ាងណា

---

[63] សូមមើល ផងដែរ វិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTY, IT/32/វិសោធនកម្មលេខ៤៧ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ វិធាន៧៣ស្ទួន(ឃ) (ការបំបែកបទចោទ) និងវិធាន៨២(ខ) (ការបំបែកការជំនុំជម្រះ សហជនជាប់ចោទ) និង វិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTR ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ វិធាន៧២ (ក) (ការបំបែកបទចោទ និងការបំបែកសវនាការ) និងវិធាន៨២ (បំបែកសវនាការ)។ នៅឯតុលាការ ICC រដ្ឋអាជ្ញាអាចកែប្រែបទចោទ ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងករណីមួយ រដ្ឋអាជ្ញា "ត្រូវបានស្នើ" យ៉ាងមានប្រសិទ្ធភាពក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ ឲ្យប្រើអំណាចរបស់ខ្លួនក្នុងការកែប្រែបទចោទ។ សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06 ប្រតិចារឹក (អង្គជំនុំជម្រះតុលាការ ICC) ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ ត្រង់ទំព័រ៣៦ បន្ទាត់ទី១០ ដល់៣៧ និងបន្ទាត់ទី១៦។

[64] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY , IT/32/Rev. 47 ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ វិធាន៧៣ស្ទួន(ឃ)។

[65] ឯកសារ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំង

ក៏ដោយ អង្គជំនុំជម្រះសម្រេចថា ដោយសារតែ "ការចោទប្រកាន់ ឬបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានទំនាក់ទំនងបន្តបន្ទាប់គ្នា នៅក្នុងដីកាបំបែកសំណុំរឿងនោះ ដូច្នេះការជំនុំជម្រះដំណាក់កាលដំបូង មិនចាំបាច់គ្របដណ្តប់លើបទចោទទាំងមូល នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ"[66]។ ដូចដែលសហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ ទាក់ទិនទៅនឹងភាពអាចទទួលយកបាននៅក្នុងផ្នែក **III** ខាងលើ ភវនីយហេតុដែលថានឹងមានការជំនុំជម្រះបន្ថែមទៀត នៅក្នុងសំណុំរឿង០០២នោះ គឺនៅឆ្ងាយមើលមិនឃើញឡើយ។ ដោយពិចារណាទៅលើភាពជាក់ស្តែងនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឱ្យធានាថា ក្នុងកម្រិតដែលអាចធ្វើទៅបាន សំណុំរឿង០០២ត្រូវគ្របដណ្តប់ទៅលើបទចោទនានានៅក្នុងសំណុំរឿងទាំងមូល។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា "ពិតជាមានការព្រួយបារម្ភថា តើជនជាប់ចោទនឹងអាចចូលរួមទាំងផ្លូវកាយ និងស្មារតីនៅក្នុងការជំនុំជម្រះដែលមានរយៈពេលវែង ឬយ៉ាងណា"[67]។ ពិសេសជាងនេះទៀត ការព្រួយបារម្ភនេះក៏ដូចគ្នាផងដែរ ទាក់ទិនទៅនឹងការជំនុំជម្រះបន្តបន្ទាប់ទៀត នៅក្នុងសំណុំរឿង០០២។

៣៤- នៅពេលដែលអង្គជំនុំជម្រះរបស់តុលាការ ICTY បានពិចារណាអំពីការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានដឹង ជាពិសេស អំពីតម្រូវការក្នុងការរក្សានូវជម្រើសនៃការគ្របដណ្តប់ទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ តាមពិត អង្គជំនុំជម្រះនៅក្នុងរឿងក្តី *Haradinaj* បានបដិសេធមិនកាត់បន្ថយវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទោះបីជានៅក្រោយពេលដែលអង្គជំនុំជម្រះបានស្នើឱ្យរដ្ឋអាជ្ញាលើកឡើងនូវវិធីនានា ក្នុងការអនុវត្តបែបនេះក៏ដោយ ពីព្រោះអង្គជំនុំជម្រះជឿជាក់ថា "ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកាត់បន្ថយបែបនេះ អាចមិនគ្របដណ្តប់ទៅលើរឿងក្តី

---

ឧបសម្ព័ន្ធ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ៣-៦ (លើកឡើងតែអំពី "បែបបទនីតិវិធីនៅ ចំពោះមុខ អ.វ.ត.ក នៅពេលដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានស្នើសុំឱ្យពិចារណាឡើងវិញ")។ សហព្រះរាជអាជ្ញាលើកឡើងថា លក្ខខណ្ឌវិនិច្ឆ័យទាំងនោះ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចលើអង្គសេចក្តីអំពីថាតើត្រូវបំបែកសំណុំរឿងបែបណានោះ អាចយកមកអនុវត្តបានចំពោះប្រព័ន្ធស៊ើបអង្កេត ទល់នឹងប្រព័ន្ធសួរតទល់គ្នា ដូច្នេះហើយ គួរតែយកមកអនុវត្តនៅ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសន្និដ្ឋានថា តួនាទីរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក គឺមិនដូចគ្នាទៅនឹងតួនាទីរបស់រដ្ឋអាជ្ញានៅតុលាការ ICTY ឡើយ ពីព្រោះដំណើរការនីតិវិធីនៅតុលាការ ICTY គឺជាកិច្ចដំណើរការនីតិវិធីតទល់គ្នា រីឯនៅ អ.វ.ត.ក គឺជា "កិច្ចដំណើរការនីតិវិធីស៊ើបអង្កេត ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានគ្រប់គ្រងដោយសមត្ថកិច្ច តុលាការ"។ ឯកសារ **E124/7** ដដែលដូចលើកយោងខាងលើ កថាខណ្ឌ ៩។

[66] ឯកសារ **E124/7** ដដែលដូចលើកយោងខាងលើ កថាខណ្ឌ ៩។

[67] ឯកសារ **E124/7** ដដែលដូចលើកយោងខាងលើ កថាខណ្ឌ ១១។

ទាំងមូលទៀតឡើយ”[68]។ ទោះបីជាកាត់បន្ថយទីតាំងឧក្រិដ្ឋកម្មដែលអង្គជំនុំជម្រះបានស្តាប់ការបង្ហាញភស្តុតាងរួចហើយក៏ដោយ ក៏អង្គជំនុំជម្រះនៅក្នុងរឿងក្តី *Šešelj* មានការប្រុងប្រយ័ត្ននៅក្នុងការធានាថា ទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍នានាដែលនៅសេសសល់ “គ្របដណ្តប់ទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់”[69] ហើយបានសង្កត់ធ្ងន់ថា ការកាត់បន្ថយភស្តុតាងទាក់ទិនទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ “នឹងពុំមានអានុភាពក្នុងការដកចេញនូវការចោទប្រកាន់នានាក្រោមបទចោទឡើយ”[70]។ ដូចដែលវិធាន៧៣ស្ទួនបានតម្រូវ អង្គជំនុំជម្រះក្នុងរឿងក្តី *Šešelj* យកចិត្តទុកដាក់អំពីប្រភេទខុសៗគ្នានិងចំនួនជនរងគ្រោះដែលទទួលរងផលប៉ះពាល់ និងវិសាលភាពភូមិសាស្ត្រនៃការចោទប្រកាន់នៅក្នុងដីកាជូនរឿងទៅជំនុំជម្រះ[71]។ ដោយទទួលស្គាល់នូវតម្រូវការក្នុងការទទួលបាន “ភាពគ្របដណ្តប់.. ដោយពិចារណាទៅលើកត្តានានាដែលមានចែងនៅក្នុងវិធាន និងដោយពិចារណាទៅលើកាលៈទេសៈពាក់ព័ន្ធទាំងអស់នៃសំណុំរឿង”[72] អង្គជំនុំជម្រះនៅក្នុងរឿងក្តី *Milutinović* បានដាក់បញ្ចូលបទចោទទាំងនោះដែលគ្របដណ្តប់ទៅលើ “លក្ខណៈជាមូលដ្ឋាន ឬមូលបទនៃសំណុំរឿង”[73]។

៣៥- អ្វីដែលសេចក្តីសម្រេចទាំងអស់នេះចង្អុលបង្ហាញនោះគឺថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែធានាថា ការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបំបែកដំណើរការនីតិវិធី គឺលើកស្ទួយកាតព្វកិច្ចផ្នែកច្បាប់ដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនូវបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ ប្រការនេះ ធានាថាការជំនុំជម្រះក្តីដែលត្រូវបានបំបែកនោះ មិនផ្តល់នូវការពិពណ៌នាមិនត្រឹមត្រូវអំពីពិរុទ្ធភាពដែលអាចមានរបស់ជនជាប់ចោទ និងមិនរារាំងជនរងគ្រោះមិនឲ្យមានឱកាសមើលឃើញយុត្តិធម៌ដែលទទួលបាននោះឡើយ។

---

[68] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Ramush Haradinaj* និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-04-84-A, សេចក្តីសម្រេចអនុលោមតាមវិធាន៧៣ស្ទួន(ឃ) (អង្គជំនុំជម្រះសាលាដំបូង ICTY) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រង់កថាខណ្ឌ ១១។

[69] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Vojislav Šešelj* សំណុំរឿងលេខ IT-03-67, សេចក្តីសម្រេចលើពាក្យសុំស្របតាមវិធាន ៧៣ស្ទួន (អង្គជំនុំជម្រះសាលាដំបូង ICTY) ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ ១០ និង១២។

[70] ដូចលើយោងខាងលើ ត្រង់កថាខណ្ឌ ៣២។

[71] ដូចលើយោងខាងលើ ត្រង់កថាខណ្ឌ ២៥ និង ៣០។

[72] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Milutinović*, សំណុំរឿងលេខ IT-05-87, សេចក្តីសម្រេចលើពាក្យសុំស្របតាមវិធាន ៧៣ស្ទួន (អង្គជំនុំជម្រះសាលាដំបូង ICTY) ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ១១។

[73] ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ១។ សូមមើល រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Radovan Karadžić*, សំណុំរឿងលេខ IT-95-5/18-I,សេចក្តីសម្រេច ជូនចំពោះរដ្ឋអាជ្ញា អនុលោមតាមវិធាន ៧៣ស្ទួន (ឃ) (អង្គជំនុំជម្រះសាលាដំបូង ICTY) ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ត្រង់កថាខណ្ឌ៣។

*iii. សេចក្តីសម្រេចដែលរងការជំទាស់មិនបានពិចារណា ឬមិនបានអនុវត្តលក្ខខណ្ឌតម្រូវស្តីពីការគ្របដណ្តប់សមស្របចំពោះបទចោទ និងមិនបំពេញបានតាមលក្ខណវិនិច្ឆ័យ "ផលប្រយោជន៍យុត្តិធម៌"*

៣៦- នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាថា តើអង្គហេតុទីតាំងឧក្រិដ្ឋកម្មដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ នោះអាចគ្របដណ្តប់ដែរ ឬទេ ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់។ តាមពិតទៅ គ្មានទីតាំងឧក្រិដ្ឋកម្មទាំងនោះទេ។ សំណុំរឿងលេខ០០២/០១ នៅពេលនេះ ផ្តោតទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាផ្នែកនៃការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំទាំងពីរ ព្រមទាំង ការសម្លាប់មន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (តែប្រភេទខ្មាំងដែល បកក បានចាត់ទុក) ក្នុងរយៈពេលកំណត់មួយខ្លីនោះនៅក្នុងទីតាំងមួយ។ ដោយគិតទៅដល់ហានិភ័យច្រើនដែលថា ជនជាប់ចោទនឹងមិនត្រូវទទួលរងការជំនុំជម្រះបន្ថែមទៀត នៅចំពោះមុខ អ.វ.ត.ក សេចក្តីសម្រេចដែលរងការជំទាស់បានដកចេញយ៉ាងមានប្រសិទ្ធភាព នូវការពិចារណាតាមផ្លូវតុលាការចំពោះអំពើឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរបំផុតមួយចំនួនដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ។ ការដកចេញនូវមន្ទីរ ស-២១ ដែលជាទីតាំងឧក្រិដ្ឋកម្មដ៏ធំ ហើយដែលជាចំណុចកណ្តាលនៃការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តដែលត្រូវបានចោទប្រកាន់ ស្តីពីការសម្លាប់សត្រូវរបស់ខ្លួន គឺជាការដកចេញពីសវនាការក្នុងវគ្គទីមួយ នូវការពិចារណាព្រឹត្តិការណ៍នានាដែលសំខាន់សម្រាប់ការយល់ដឹងឲ្យបានត្រឹមត្រូវចំពោះសំណុំរឿង០០២ទាំងមូល។ ក្នុងលក្ខណៈដែលផ្ទុយគ្នាទាំងស្រុង ជាមួយការអនុវត្តនៅកម្រិតអន្តរជាតិនោះ ការបំបែកបែបនេះមិនអាចគ្របដណ្តប់ឲ្យឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដោយគិតទៅដល់ការកំណត់ប្រភេទនៃបទចោទ លក្ខណៈ ព្រមទាំងទំហំ នៅពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើង ព្រមទាំងផលប៉ះពាល់នៃឧក្រិដ្ឋកម្មនោះទៅលើជនរងគ្រោះ។

៣៧- ការដកចេញនូវភាពគ្របដណ្តប់តូចមួយនៃមន្ទីរសន្តិសុខ ព្រមទាំងទីតាំងសម្លាប់មនុស្សចេញពីក្នុងសវនាការវគ្គមួយ នឹងនាំទៅដល់ស្ថានភាពមួយដែលជនជាប់ចោទដែលជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ អាចនឹងមិនត្រូវបានទទួលការជំនុំជម្រះចំពោះឧក្រិដ្ឋកម្មសំខាន់ៗមួយចំនួន ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងនោះ។ ផលប៉ះពាល់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងជនរងគ្រោះរាប់លាននាក់ ដែលសហព្រះរាជអាជ្ញាការពារ មិនគួរត្រូវបានមើលរំលងនោះឡើយ។

៣៨- ជាងនេះទៀត លក្ខណៈតូចចង្អៀតមិនត្រឹមត្រូវនៃសំណុំរឿង០០២/០១ ដូចដែលបានកំណត់ដោយសេចក្តីសម្រេចដែលរងការជំទាស់នេះ នឹងកាត់បន្ថយនូវឥទ្ធិពលរបស់ អ.វ.ត.ក ទៅលើការផ្សះផ្សាជាតិក្នុងប្រទេសកម្ពុជា ក៏ដូចជាការបង្កើតនូវកំណត់ប្រវត្តិសាស្ត្រត្រឹមត្រូវ អំពីឧក្រិដ្ឋកម្មនានា

ដែលបានប្រព្រឹត្តឡើងដោយគោរពតាមគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ មហាសន្និបាតអង្គការសហប្រជាជាតិ បានទទួលស្គាល់នូវកិច្ចស្វែងរកការផ្សះផ្សាជាតិ និងយុត្តិធម៌ដែលជាគោលដៅគន្លឹះមួយរបស់ អ.វ.ត.ក[74]។ អង្គបុរេជំនុំជម្រះបានសម្រេចថា៖

> *កិច្ចព្រមព្រៀងរបស់ អវតក បានបង្ហាញដល់ចៅក្រម ក៏ដូចជាអង្គជំនុំជម្រះនៅ អ.វ.ត.ក ឲ្យស្វែងរកទាំងការពិត ស្តីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ជាពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដែលនេះជាផ្នែកមួយនៃការផ្សះផ្សាជាតិ[75] ។*

៣៩- សារៈសំខាន់នៃការបង្កើតជាកំណត់ប្រវត្តិសាស្ត្រដែលត្រឹមត្រូវស្តីពីឧក្រិដ្ឋកម្មមានទ្រង់ទ្រាយធំ នៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការអន្តរជាតិ ក៏ត្រូវបានទទួលស្គាល់ដោយតុលាការ ICTY ផងដែរ។ នៅក្នុងរឿងក្តី *Nikolić* អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់តួនាទីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងការចូលរួមចំណែកស្វែងរក "ការពិតអំពីការប្រព្រឹត្តបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍...ដោយបង្កើតនូវកំណត់ហេតុប្រវត្តិសាស្ត្រមួយដែលត្រឹមត្រូវ និងដែលអាចទទួលយកបាន[76]។

៤០- ហេតុនេះ ទោះក្នុងករណីចាំបាច់ក៏ដោយ ការសម្រេចបំបែកដីកាដំណោះស្រាយ ត្រូវតែធ្វើឡើងក្នុងលក្ខណៈមួយដែលសម្រួលដល់ការសម្រេចឲ្យបាននូវកំណត់ហេតុប្រវត្តិសាស្ត្រមួយ ដែលត្រឹមត្រូវ យុត្តិធម៌ និងការផ្សះផ្សាជាតិ។ ក្នុងករណីបច្ចុប្បន្ននេះ ការផ្តោតទៅលើដំណាក់កាលពីរដំបូងនៃការផ្លាស់ទីកន្លែងដោយបង្ខំ និងការសម្លាប់អតីតមន្ត្រីខ្មែរក្រហមនៅក្នុងទីតាំងមួយ ក្នុងអំឡុងពេលកំណត់មួយ នឹងបន្ថយដំណើរទៅមុខរបស់តុលាការឆ្ពោះទៅសម្រេចគោលដៅទាំងនេះទេ។

---

[74] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៧/២២៨ ដែលមានចំណងជើងថា ការជំនុំជម្រះក្តីលើពួកខ្មែរក្រហម U.N. Doc. No. A/RES/57/228 ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២00៣ ត្រង់កថាខណ្ឌ ២, វិធានផ្ទៃក្នុង បុព្វកថា កថាខណ្ឌ ២។

[75] **D404/2/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២0១១ ត្រង់កថាខណ្ឌ ៦៥។

[76] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolic*, សំណុំរឿងលេខ IT-02-60/1-S, សាលក្រមផ្តន្ទាទោស (អង្គជំនុំជម្រះសាលាដំបូង ICTY), ថ្ងៃទី២ ខែធ្នូ ឆ្នាំ២00៣ ត្រង់កថាខណ្ឌ ៦0។

៤១- សម្រាប់ហេតុផលទាំងនេះ សហព្រះរាជអាជ្ញាលើកឡើងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណា និងមិនអនុវត្តគោលការណ៍នីត្យានុកូលភាពឲ្យបានត្រឹមត្រូវ និងការពិចារណាទៅលើអង្គហេតុនោះដែលមានន័យស្មើនឹងកំហុសអង្គច្បាប់ ឬកំហុសជាក់លាក់ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន។ ប្រសិនបើអង្គជំនុំជម្រះអនុវត្តបានត្រឹមត្រូវចំពោះគោលការណ៍ជាធរមាន នោះអង្គជំនុំជម្រះប្រាកដជាទទួលយកសំណើសមហេតុផលរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១មិនខាន។ ហេតុនេះ កំហុសរបស់អង្គជំនុំជម្រះបានមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់ និងបណ្តាលឲ្យប៉ះពាល់ដល់សហព្រះរាជអាជ្ញា។

**ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយខកខានមិនបានចេញសេចក្តីសម្រេចដែលសមស្របទៅតាមទម្រង់ និងខ្លឹមសារ រួមទាំងការផ្តល់នូវសំអាងហេតុពេញលេញផង**

៤២- សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយខកខានមិនបានផ្តល់សំអាងហេតុឲ្យបានពេញលេញ ចំពោះសេចក្តីសម្រេចដែលរងការជំទាស់ មិនបំពេញទៅតាមបទដ្ឋានដែលអង្គជំនុំជម្រះនេះបានកំណត់ រួមទាំងគោលការណ៍អន្តរជាតិជាធរមានផងដែរ។

៤៣- ច្បាប់ជាធរមានស្តីពីសេចក្តីសម្រេចដែលមានសំអាងហេតុ បង្ហាញយ៉ាងច្បាស់ថា ស្ថាប័នតុលាការមានភារកិច្ចផ្តល់នូវសេចក្តីសម្រេចដែល *ទម្រង់* របស់វាឆ្លុះបញ្ចាំងអំពីចំណាត់ការតាមផ្លូវតុលាការ និងដែល*ខ្លឹមសារ*របស់វាគឺផ្តល់សំអាងហេតុពេញលេញ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការសង្កេតក្នុងការសម្រេចទៅលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីថា៖

> *អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ជាបឋម សេចក្តីសម្រេចរបស់តុលាការត្រូវតែបង្ហាញ* ការបញ្ជាក់ណាមួយ *អំពីចំណាត់ការតាមផ្លូវតុលាការដែលច្បាប់អនុញ្ញាត។ ត្រង់ចំណុចនេះ ជាការចាំបាច់ដែលសេចក្តីសម្រេចមួយតាមផ្លូវតុលាការត្រូវចាត់ការលើបញ្ហាអង្គច្បាប់ ដែលស្ថិតនៅចំពោះមុខខ្លួនឲ្យបានច្បាស់លាស់។ ហេតុដូច្នេះ សេចក្តីសម្រេចតាមផ្លូវតុលាការគួរតែប្បីមានផ្នែកមួយដែលមានអានុភាព ("ខ សម្រាប់អនុម័ត" ឬ "ផ្នែកសម្រេចសេចក្តី") ដែលដោះស្រាយចំពោះអង្គសេចក្តី ហើយ/ឬ បញ្ហានីតិវិធី ដោយបង្កើត កែប្រែ បដិសេធចោល ឬទទួលយកនូវទំនាក់ទំនងដែលសំអាងលើច្បាប់ ដែលមានជាប់ពាក់ព័ន្ធទៅនឹងភាគីនានា។ ... ជាងនេះទៀត ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងឱកាសខុសៗគ្នាថា រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថា ជាសេចក្តីសម្រេចផ្ទាល់*

*មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលវិបាកនៃការគោរពសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាការពិតណាស់ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញ គឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ*[77] ។

៤៤- ដូចគ្នានេះដែរ លក្ខន្តិកៈសម្រាប់អនុវត្តនៅតុលាការ ICC, តុលាការ ICTY និងតុលាការ ICTR តម្រូវឲ្យមានសំអាងហេតុត្រឹមត្រូវក្នុងសេចក្តីសម្រេច[78]។ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTY បានសម្រេចថា សេចក្តីសម្រេចមានសំអាងហេតុ ជួយធានានូវគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ដែលគ្រប់គ្រងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ និងសិទ្ធិប្តឹងសាទុក្ខ[79]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង "មានកាតព្វកិច្ចទូទៅមួយគឺបញ្ចេញយោបល់ដែលមានសំអាងហេតុ"[80] ដែលផ្តល់សំអាងហេតុគ្រប់គ្រាន់សម្រាប់ការវាយតម្លៃរបស់ខ្លួន និង "ផ្តល់តុល្យភាពពេញលេញដល់កត្តាទាំងអស់ដែលពាក់ព័ន្ធ"[81]។ "វិសាលភាពនៃការផ្តល់សំអាងហេតុរបស់អង្គជំនុំ

[77] ឯកសារលេខ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ២៥ [សម្រង់ក្នុងអត្ថបទត្រូវបានលុបចោល]។

[78] *សូមមើល* លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, សេចក្តីសម្រេចលេខ S.C. Res 827, មាត្រា ២៣ (ឆ្នាំ១៩៩៣); លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា, សេចក្តីសម្រេចលេខ S.C. Res 955, មាត្រា ២២ (ឆ្នាំ១៩៩៤); លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, អនុម័តដោយសន្និសីទការទូតរបស់ អ.ស.ប, មាត្រា ៧៤ (ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨)។

[79] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤, ឯកសារលេខ 999 U.N.T.S. 171 (ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៦)។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolić,* សំណុំរឿងលេខ IT-02-60/1-A, សាលដីកាលើបណ្តឹងសាទុក្ខផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ៩៦; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-96-23 & IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ត្រង់កថាខណ្ឌ ៤១។

[80] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolić,* សំណុំរឿងលេខ IT-02-60/1-A, សាលដីកាលើបណ្តឹងសាទុក្ខផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ ៩៦។

[81] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-96-23 & IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ត្រង់កថាខណ្ឌ ៣២៤។

ជម្រះ នឹងពឹងផ្អែកទៅលើកាលៈទេសៈនៃរឿងក្តី”[82]។ ទោះជាយ៉ាងណាក្តី ជាកម្រិតអប្បបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវ “ផ្តល់សំអាងហេតុក្នុងការគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន ទៅលើការពិចារណាលើអង្គសេចក្តី ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន”[83]។ សហព្រះរាជអាជ្ញាលើកឡើងដោយគោរពថា សេចក្តីសម្រេចដែលរងការជំទាស់ មិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងនេះទេ។

៤៥- ទីមួយ ពាក់ព័ន្ធនឹងលក្ខខណ្ឌជា*ទម្រង់*សម្រាប់ចេញសេចក្តីសម្រេចតាមផ្លូវតុលាការដែលអង្គជំនុំជម្រះបានសម្រេចនោះ សហព្រះរាជអាជ្ញាសង្កេតឃើញថា សេចក្តីសម្រេចដែលរងការជំទាស់ រៀបចំឡើងជាទម្រង់នៃអនុស្សរណៈដែលមាន៤កថាខណ្ឌផ្ញើជូនទៅភាគី ដោយមានហត្ថលេខារបស់ប្រធាន ដែលក្នុងនោះកថាខណ្ឌចំនួន៣ ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលរងការជំទាស់។ ពុំមានផ្នែកប្រតិបត្តិការជាផ្លូវការ, អនុម័តបទបញ្ញត្តិ ឬ សេចក្តីសម្រេចទេ។ តាមពិត ដូចដែលបានលើកឡើងក្នុងកថាខណ្ឌ២១ ខាងលើរួចមកហើយ គឺថាផលវិបាកតាមផ្លូវច្បាប់របស់សេចក្តីសម្រេចដែលរងការជំទាស់ (សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដកចេញចុងក្រោយនូវការពិចារណាអំពីទីតាំងបន្ថែមទៀតណាមួយ ក្នុងសំណុំរឿងលេខ00២/0១) លេចឡើងយ៉ាងពេញលេញតាមរយៈអនុស្សរណៈបន្តបន្ទាប់ដែលផ្ញើចេញដោយអង្គជំនុំជម្រះសាលាដំបូង[84]។ ហេតុនេះ ទម្រង់របស់សេចក្តីសម្រេចដែលរងការជំទាស់ មិនស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា សេចក្តីសម្រេចត្រូវ “បង្ហាញ

---

[82] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06 (OA 5), សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា “សេចក្តីសម្រេចលើកទី១ ទៅលើសំណើរបស់រដ្ឋអាជ្ញា និងសំណើសុំកោសលុបដែលបានកែប្រែអនុលោមតាមវិធាន ៨១” (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICC), ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២00៦ ត្រង់កថាខណ្ឌ ២0។

[83] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Édouard Karemera*, សំណុំរឿងលេខ ICTR-98-44-AR73.1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Mathieu Ngirumpatse ដែលជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២00៨ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTR), ថ្ងៃទី៣0 ខែមករា ឆ្នាំ២00៩ ត្រង់កថាខណ្ឌ ១៩។

[84] ឯកសារលេខ **E223/2** អនុស្សរណៈដែលមានចំណងជើងថា “សវនាការដេញដោលលើឯកសារពេលខាងមុខ និងឆ្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223), ថ្ងៃទី១៩ ខែតុលា ឆ្នាំ២0១២ ត្រង់កថាខណ្ឌ ៣។

*ការបញ្ជាក់ណាមួយ* អំពីចំណាត់ការតាមផ្លូវតុលាការដែលច្បាប់អនុញ្ញាត"[85]។ នេះជាការបារម្ភពិសេសមួយដោយពិចារណាថា បញ្ហាដែលសេចក្តីសម្រេចត្រូវឆ្លើយតប គឺជាសារៈសំខាន់តាមផ្លូវច្បាប់យ៉ាងធំធេង និងជាប្រវត្តិសាស្ត្រ និងជាចំណុចសំខាន់នៃសំណុំរឿង០០២ ផងដែរ។

៤៦- បន្ថែមទៀត តាមវិធានផ្ទៃក្នុង អនុស្សរណៈពុំមានអំណាចគតិយុត្តទេ។ ខណៈដែលសេចក្តីសម្រេចលើបញ្ហាខ្លឹមសារត្រូវតែចេញតាមលំនាំបែបនេះនោះ ភាគីត្រូវស្ថិតក្នុងជំហរមិនច្បាស់លាស់ពាក់ព័ន្ធនឹង៖ ពេលវេលា និងភាពដែលអាចប្តឹងសាទុក្ខបាន ការសម្រេចជាឯកច្ឆន្ទនៃមតិភាគច្រើនលើសលប់របស់ចៅក្រម និងថាតើនីតិវិធីនៃការសម្រេចសេចក្តីនេះមានភាពខុសប្លែកពីសេចក្តីសម្រេចដែលបានចេញហើយ នៅពេលសេចក្តីសម្រេចនោះចេញជាផ្លូវការ ជាលាយលក្ខណ៍អក្សរ ឬយ៉ាងណា។

៤៧- ទីពីរ ពាក់ព័ន្ធនឹង*ខ្លឹមសារ* នៃសេចក្តីសម្រេចដែលរងការជំទាស់វិញ សហព្រះរាជអាជ្ញាបានលើកឡើងជាទឡ្ហីករណ៍ខាងលើថា សេចក្តីសម្រេចដែលរងការជំទាស់មិនបានបញ្ចូលការពិចារណាលើ "កត្តាពាក់ព័ន្ធ" ជាមូលដ្ឋានទេ[86] គឺបទដ្ឋានអន្តរជាតិដែលអាចអនុវត្តដោយផ្ទាល់ទៅលើការបំបែកការចោទប្រកាន់។ បើតាមបទដ្ឋានអន្តរជាតិជាធរមានខាងលើ ប្រការនេះបង្ហាញថា សេចក្តីសម្រេចដែលរងការជំទាស់មានសំអាងហេតុពុំពេញលេញទេ។ សំអាងហេតុដោយសង្ខេបដែលបានលើកឡើងដើម្បីគាំទ្រដល់សេចក្តីសម្រេចដែលរងការជំទាស់ គឺជាការសន្មតបែបស្មានៗ ដែលសហព្រះរាជអាជ្ញានឹងបង្ហាញជូនទាំងអស់ (ក្នុងផ្នែក **(គ)** ខាងក្រោម) ដែលមិនមានសម្អាងហេតុ។

៤៨- ជាងនេះទៀត សេចក្តីសម្រេចដែលរងការជំទាស់មិនបានផ្តល់សំអាងហេតុ សម្រាប់ធ្វើយុត្តិកម្មពីការផ្លាស់ប្តូរទស្សនៈជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងទេ។ នៅក្នុងសេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញ នៅពេលបើកចំហសម្រាប់បន្ថែមទីតាំងឧក្រិដ្ឋកម្ម ក្នុងសំណុំរឿងលេខ០០២/០១ អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនអាចយកតាមយោបល់របស់សហព្រះរាជអាជ្ញាចំពោះការចោទប្រកាន់ជាអាទិភាពសម្រាប់ការពិចារណា ក្នុងដំណាក់កាលសវនាការក្រោយៗទៀត[87]។ ដូចបានលើកឡើង

[85] ឯកសារលេខ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ២៥។

[86] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-96-23 & IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY), ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ ត្រង់កថាខណ្ឌ ៣២៤។

[87] **E124/7** សេចក្តីសម្រេចលើសំណើររបស់សហព្រះរាជអាជ្ញា ដែលសុំឱ្យពិនិត្យឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងសំណើសុំពាក់ពន្ធនានា និងឧបសម្ព័ន្ធ, ១៨ តុលា ២០១១, ត្រង់កថាខណ្ឌទី១២។

នៅក្នុងផ្នែកប្រវត្តិនីតិវិធីរួចហើយ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា ការបន្ថែមមន្ទីរសន្តិសុខស-២១ និងទីតាំងសម្លាប់នៅស្រុក១២ "អាចជាការភ្ជាប់ទំនាក់ទំនងជាមួយលំដាប់លំដោយកាលប្បវត្តិត្រឹមត្រូវ នៃហេតុការណ៍ដែលនឹងត្រូវស្តាប់ក្នុងសវនាការនៃសំណុំរឿង០០២/០១"[88]។ ពីរខែក្រោយមក នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិសាលភាពបែបនេះនឹង "ធ្វើឲ្យសវនាការលើសំណុំរឿង០០២/០១ អូសបន្លាយពេលយូរ" ដោយបញ្ជាក់ថា "អង្គជំនុំជម្រះនៅតែយល់ឃើញថា ទីតាំងឧក្រិដ្ឋកម្មទាំងនេះ មិនជាប់ពាក់ព័ន្ធជិតស្និទ្ធទៅនឹងការចោទប្រកាន់ចំពោះអង្គហេតុក្នុងសំណុំរឿង ០០២/០១ ឬថាការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងនេះ មិនសមស្របតាមលំដាប់លំដោយត្រឹមត្រូវនៃការជំនុំជម្រះទេ"[89]។ ពុំមានផ្តល់ការពន្យល់ណាមួយចំពោះការកែប្រែជាមូលដ្ឋានចំពោះទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាស្នូលក្នុងសំណុំរឿងលេខ០០២ទេ។ ការខកខានមិនបានផ្តល់សម្អាងហេតុគ្រប់គ្រាន់ កាន់តែមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់បន្ថែមទៀត។

### គ. កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិចារណាអំពីហានិភ័យ នៃ "ការពន្យារពេលសវនាការយ៉ាងយូរ" និងទំនាក់ទំនងរវាងទីតាំងនានា

៤៩- សេចក្តីសម្រេចដែលរងការជំទាស់ បានដកមន្ទីរស-២១ ព្រមទាំងការសម្លាប់មនុស្សក្នុងស្រុក ១២ ចេញពីវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ដោយផ្អែកលើមូលដ្ឋាន៖

ក) "ហានិភ័យនៃការពន្យារពេលសវនាការយ៉ាងយូរ ក្នុងសំណុំរឿង០០២/០១" ដែលអាចបណ្តាលមកពី (១) លទ្ធភាពដែលថាក្រុមមេធាវីការពារក្តីអាចនឹងជំទាស់ទៅនឹងការពង្រីកវិសាលភាពដែលបានស្នើឡើង, (២) ភាគស្មុគស្មាញដែលរំពឹងទុកជាមុនពាក់ព័ន្ធទៅនឹងការកម្រិតកំណត់លើវិសាលភាពនៃការពង្រីកវិសាលភាព និង(៣) ចំនួនសាក្សីដែលភាគីនានាស្នើឡើង។

ខ) ទំនាក់ទំនងដែលមិនគ្រប់គ្រាន់ (បានបង្ហាញ) រវាងទីតាំងឧក្រិដ្ឋកម្មទាំងនោះ ជាមួយការចោទប្រកាន់ទៅលើអង្គហេតុដែលបានធ្វើឡើងក្នុងសំណុំរឿង០០២/០១ ឬក៏កង្វះខាតនូវលំដាប់លំដោយដែលសមស្រប សម្រាប់ការដាក់បន្ថែមនូវទីតាំងឧក្រិដ្ឋកម្មដែលបានស្នើឡើងចូលទៅក្នុងសវនាការក្នុងពេលបច្ចុប្បន្ន។

[88] ឯកសារលេខ **E218.1** អនុស្សរណៈដែលមានចំណងជើងថា "សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163)", ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៣។

[89] ឯកសារលេខ **E163/5** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌ ២។

គ) ការពន្យារពេលដែលបណ្តាលមកពីបញ្ហានានាដូចជាបញ្ហា សុខភាព ឬសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសវនាការ[90]។

៥០- សហព្រះរាជអាជ្ញាសូមលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុស (ទាំងផ្នែកអង្គហេតុ អង្គច្បាប់ ទាំងការប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួន) ក្នុងបណ្តាកំហុសនានា ដោយអង្គជំនុំជម្រះមិនបានអនុវត្តនូវលក្ខណវិនិច្ឆ័យផ្លូវច្បាប់ត្រឹមត្រូវ ដោយបានគិតគូរដល់ការពិចារណាដែលមិនពាក់ព័ន្ធនានា ព្រមទាំងមិនបានវិភាគឲ្យបានត្រឹមត្រូវទៅលើកត្តានានាដែលប៉ះពាល់ដល់រយៈពេលនៃសវនាការ និងការយល់ខុសចំពោះទំនាក់ទំនងរវាងបញ្ហាក្នុងពេលបច្ចុប្បន្ន ដែលត្រូវដោះស្រាយក្នុងសំណុំរឿង ០០២/០១ ជាមួយនឹងទីតាំងបន្ថែមដែលបានស្នើឡើង។ បើទោះបីជាពិចារណាដោយឡែក ឬពិចារណាជារួម ក៏កំហុសផ្នែកអង្គហេតុ ផ្នែកអង្គច្បាប់ និងផ្នែកឆន្ទានុសិទ្ធិ (តាមដែលអាចអនុវត្តបាន) បានធ្វើឲ្យមោឃភាពដល់សេចក្តីសម្រេចដែលរងការជំទាស់ ហើយបណ្តាលឲ្យមានភាពមិនយុត្តិធម៌ ព្រមទាំងបង្កឲ្យមានភាពអយុត្តិធម៌ចំពោះសហព្រះរាជអាជ្ញា។ ហេតុផលសាមញ្ញគឺថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តដោយត្រឹមត្រូវនូវអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធ ឬក៏ប្រើប្រាស់ដោយត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួន អាចនាំឲ្យមានសេចក្តីសម្រេចផ្សេង គឺដាក់បញ្ចូលនូវទីតាំងដែលបានស្នើឡើងទៅក្នុងសំណុំរឿង០០២/០១។ នៅក្នុងផ្នែកមួយនេះ ក្នុងបណ្តឹងសាទុក្ខនេះ នឹងលើកឡើងពីចំណុចនីមួយៗ នៃការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានរៀបរាប់ពីខាងលើ។

*i. ការពឹងផ្អែកទៅលើ "ការរំពឹងទុកជាមុនពីការជំទាស់របស់មេធាវីការពារក្តី"*

៥១- ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះ "លទ្ធភាពដែលថាមេធាវីការពារក្តីអាចជំទាស់" ចំពោះការដាក់បញ្ចូលនូវមន្ទីរស-២១ និងទីតាំងសម្លាប់មនុស្សនៅស្រុក១២ ថាជាកត្តាមួយដែលអាចជាហានិភ័យចំពោះការពន្យារពេលសវនាការយ៉ាងយូរនោះ គឺអាចចាត់ទុកថាជាកំហុសផ្នែកអង្គច្បាប់ និង/ឬអង្គហេតុ។

៥២- ទីមួយ ការរំពឹងទុកជាមុនពីការជំទាស់ពីភាគីនានា គឺមិនមែនជាកត្តាត្រឹមត្រូវតាមច្បាប់នោះឡើយ ក្នុងការពិចារណានៅពេលបំបែកសំណុំរឿង ឬក៏នៅពេលសម្រេចពីលក្ខខណ្ឌជាក់លាក់នៃការបំបែកកិច្ចនីតិវិធី។ មុខងារស្នូលមួយរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រូវដោះស្រាយនូវរាល់ទំនាស់រវាងភាគីនានា ហើយការពិតដែលថាភាគីណាមួយអាចនឹងលើកយកនូវបញ្ហាដែលពាក់ព័ន្ធនឹងសេចក្តីសម្រេច

[90] ឯកសារលេខ E163/5 ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ ២។

របស់អង្គជំនុំជម្រះសាលាដំបូង នឹងមិនមានផលប៉ះពាល់ចំពោះការអនុវត្តច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងនោះដែរ។

៥៣- ទីពីរ គឺអង្គជំនុំជម្រះសាលាដំបូងមានកំហុសផងដែរដោយធ្វើការពិចារណាថា ការជំទាស់របស់មេធាវីការពារក្តីអាចនឹងធ្វើឲ្យយឺតខ្លាំងដល់ដំណើរការសវនាការ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១២ មេធាវីការពារក្តីត្រូវបានអញ្ជើញឲ្យធ្វើការសន្និដ្ឋានពាក់ព័ន្ធទៅនឹងការពង្រីកវិសាលភាពនៃការជំនុំជម្រះ ជាការឆ្លើយតបចំពោះការជូនដំណឹងជាលាយលក្ខណ៍អក្សរពីជំហររបស់សហព្រះរាជអាជ្ញាដែលបានដាក់ចេញកាលពីពេលមុន[91]។ ក្រុមមេធាវីការពារក្តីនីមួយៗ បានយកឱកាសនេះដាក់បញ្ចូលនូវការសន្និដ្ឋានរបស់ខ្លួនទៅក្នុងកំណត់ហេតុ[92]។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងចេញនូវសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះនោះ រាល់ការជំទាស់បន្ថែមរបស់មេធាវីការពារក្តីនឹងមិនមានប្រយោជន៍ទាល់តែសោះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងត្រឹមត្រូវជាច្រើនដងរួចមកហើយថា នៅពេលសេចក្តីសម្រេចរបស់ខ្លួនត្រូវបានប្តឹងសាទុក្ខ ទៅអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងមិនបើកចំហទេចំពោះការតវ៉ា ឬការរិះគន់ពីសំណាក់ភាគីក្នុងដំណើរការនីតិវិធី[93]។ ដូច្នេះ គ្មាន "ការជំទាស់"ណាមួយរបស់មេធាវីការពារក្តី ដែលបានធ្វើឡើងបន្ទាប់ពីចេញសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង អាចបង្កឲ្យមានការពន្យាពេលសវនាការនោះឡើយ។

---

[91] ឯកសារលេខ **E1/114.1** ប្រតិចារឹក ទំព័រ ៩៣, បន្ទាត់ ៧ និងខ្លឹមសារបន្តបន្ទាប់ខាងក្រោមទៀត។

[92] សូមមើល ឧទាហរណ៍ ឯកសារលេខ E1/114.1 ដូចលើកយោងខាងលើ ត្រង់ទំព័រ១០៥ បន្ទាត់១២ និងខ្លឹមសារខាងក្រោម ទំព័រ១១៣ បន្ទាត់៥ និងខ្លឹមសារខាងក្រោម ទំព័រ១១៦ បន្ទាត់១២ និងខ្លឹមសារខាងក្រោម។

[93] សូមមើល ឧទាហរណ៍៖ ឯកសារលេខ **E214** សេចក្តីសម្រេចលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា, ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ១២; និងឯកសារលេខ **E214/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីបន្ថែម៖ ការបន្តកំហុសវិជ្ជាជីវៈរបស់មេធាវី ដែលបានចុះបញ្ជីក្នុងគណៈមេធាវីរបស់លោក" ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ត្រង់ទំព័រ ២ (ដោយដកស្រង់ការសម្រេចរបស់ចៅក្រម Lavergne នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២៖ "ទាំពេលសវនាការកាលពីព្រឹកមិញនោះ មេធាវី អ៊ីនូហ្ស៊ី ដែលជាមេធាវីអន្តរជាតិរបស់ក្រុមការពារក្តីលោក នួន ជា ជាថ្មីម្តងទៀត បានធ្វើការអត្ថាធិប្បាយសំដៅបដិសេធ និងទិតៀនដល់សេចក្តីសម្រេចដែលអង្គជំនុំជម្រះបានចេញរួចហើយក្នុងនាមតុលាការទាំងមូលទាក់ទងនឹងការដឹកនាំសវនាការ។ ការធ្វើអត្ថាធិប្បាយនេះនោះ គឺថាបានធ្វើឡើងនៅក្នុងខណៈដែលគាត់ហ្នឹងត្រូវបានព្រមានជាច្រើនដងហើយថា អាកប្បកិរិយាបែបនេះមិនសមស្របទេ ហើយមិនត្រូវបន្តធ្វើទៀតទេ")។

### *ii. ការពឹងផ្អែកទៅលើភាពស្មុគស្មាញក្នុងការ "កម្រិតកំណត់វិសាលភាពនៃការពង្រីកវិសាលភាពដែលបានស្នើឡើង"*

៥៤- ក្នុងការសន្និដ្ឋានដែលថា ការពង្រីកវិសាលភាពសំណុំរឿង០០២/០១ ដើម្បីបញ្ចូលមន្ទីរស-២១ និងទីតាំងឧក្រិដ្ឋកម្មក្នុងស្រុក១២ អាចនាំឲ្យមានហានិភ័យដល់ការពន្យារពេលយ៉ាងយូរនោះ គឺអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែកបន្ថែមទៀតទៅលើភាពស្មុគស្មាញតាមការរំពឹងទុក ក្នុងការកម្រិតកំណត់វិសាលភាពនៃការពង្រីកវិសាលភាពដែលបានស្នើឡើង ហើយវាជាការរំពឹងទុកដែលមិនជាក់លាក់ទៀត[94]។ សហព្រះរាជអាជ្ញាលើកឡើងថា ការពឹងផ្អែកបែបនេះអាចចាត់ទុកថាជាកំហុសយ៉ាងជាក់ច្បាស់ ក្នុងការប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាពីសិទ្ធិអំណាចដែលខ្លួនមាន ក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធី និងក្នុងការត្រួតត្រាទៅលើវិសាលភាពនៃភស្តុតាងដែលត្រូវលើកយកមកបង្ហាញ។

៥៥- អង្គជំនុំជម្រះសាលាដំបូងមានអំណាចយ៉ាងទូលំទូលាយ (ព្រមទាំងមានកាតព្វកិច្ច) ក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីឲ្យមានប្រសិទ្ធភាព ហើយតាមពិតទៅអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់រួចហើយនូវអំណាចទាំងអស់នេះក្នុងពេលសវនាការ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចក្នុងការកំណត់ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលខ្លួនត្រូវស្តាប់ក្នុងដំណាក់កាលនីមួយៗនៃការជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏មានសិទ្ធិកំណត់ពេលវេលាដែលត្រូវផ្តល់ឲ្យភាគីនានាក្នុងការសួរដេញដោលលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងនោះ[95]។ អង្គជំនុំជម្រះសាលាដំបូងក៏បានប្រើប្រាស់នូវសិទ្ធិអំណាចបែបនេះ ក្នុងការសម្រេចលើសាក្សីដែលខ្លួនត្រូវកោះហៅ ព្រមទាំងបង្កើត និងកែសម្រួលលំដាប់លំដោយដែលត្រូវកោះហៅ ព្រមទាំងការចេញបញ្ជាកំណត់ពេលវេលាជាក់លាក់ សម្រាប់ការសួរដេញដោលបុគ្គលនីមួយៗដែលខ្លួនត្រូវស្តាប់ក្នុងពេលកន្លងមកហើយ[96]។ អង្គជំនុំជម្រះសាលាដំបូងមានអំណាចកំណត់ និងកម្រិតទៅលើវិសាលភាពនៃ

---

[94] ឯកសារលេខ E163/5, សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

[95] វិធាន ៨៤, ៨៥, ៩១, ៩១*ស្ទួន* នៃវិធានផ្ទៃក្នុង។

[96] សូមមើល ឧទាហរណ៍ ឯកសារលេខ **E131/1.1** ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២; ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១ ឯកសារលេខ **E35/2** សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ និងការដាក់អញ្ញត្រកម្ម, ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១, ត្រង់កថាខណ្ឌ ១១ ("យោងតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក សេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាថា តើបុគ្គលណាដែលត្រូវគេសួរដេញដោលគឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ"); ឯកសារលេខ **E141** ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅថ្ងៃទី

បញ្ហាដែលត្រូវសួរដេញដោលចំពោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ[97] ហើយអង្គជំនុំជម្រះក៏បានប្រើប្រាស់អំណាចនេះរួចហើយដោយការផ្ដល់ការណែនាំ ទៅលើបញ្ហាដែលពាក់ព័ន្ធនានា[98] ព្រមទាំងហាមឃាត់មិនឱ្យសួរសំណួរណាដែលខ្លួនគិតថាពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលស្ថិតនៅក្រៅវិសាលភាពនៃសវនាការក្នុងពេលបច្ចុប្បន្ន[99]។ អង្គជំនុំជម្រះសាលាដំបូងក៏មានអំណាចផងដែរក្នុង

---

១៨ ខែវិច្ឆិកា ឆ្នាំ២០១១, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១, ត្រង់ទំព័រ ៤ (“ពេលវេលាកំណត់នឹងត្រូវធ្វើឡើងដោយអង្គជំនុំជម្រះ ក្នុងករណីយល់ឃើញថាចាំបាច់”); ឯកសារលេខ **E93** សេចក្ដីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ, ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ត្រង់ទំព័រ ១ ; ឯកសារលេខ **E172/29** សាក្សីជាបន្តបន្ទាប់នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃសំណុំរឿង០០២/០១, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២; ឯកសារលេខ **E233** សេចក្ដីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១២; ឯកសារលេខ **E236/1** ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង០០២/០១, ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២។

[97] វិធាន ៨៥(១), ៩១(២) នៃវិធានផ្ទៃក្នុង; សូមមើលផងដែរ មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[98] សូមមើលឧទាហរណ៍ ឯកសារលេខ **E141** ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១, ត្រង់ទំព័រ ៣ (“សំណួរដែលត្រូវសួរជនជាប់ចោទនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃបន្តបន្ទាប់ទៀត នឹងចាប់ផ្ដើមជាមួយនឹងសំណួរទាក់ទងនឹងសាវតារប្រវត្តិ(ខាងលើ)។ ក្នុងករណីណាក៏ដោយ ក៏ការចោទសួរនេះត្រូវកម្រិតនៅត្រឹមប្រធានបទទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ”); ឯកសារលេខ **E145** សេចក្ដីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់ ទំព័រ ៣ (ភាសាអង់គ្លេស) (“... ភាគីអាចសួរសំណួរពួកគាត់លើចំណុចផ្សេងៗដែលពួកគាត់បានដឹងពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង*០០២/០១*។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះនឹងពុំអនុញ្ញាតឱ្យមានការសួរសំណួរលើចំណុចអង្គហេតុនានាដែលពុំស្ថិតក្នុងវិសាលភាពនៃសវនាការនេះឡើយ”)។

[99] សូមមើលឧទាហរណ៍ ឯកសារលេខ **E1/17/1** ប្រតិចារឹក, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ ត្រង់ទំព័រ ៦៦ បន្ទាត់ ៨-២២ (ភាសាអង់គ្លេស) (ប្រធានអង្គជំនុំជម្រះ៖ “... សូមកំណត់សួរច្បាស់លាស់កាលបរិច្ឆេទនៃសំណួរផង ពីព្រោះបើសិនណា យើងប្រើសំណួរណាដែលហួសពីវិសាលភាពនៃអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការលើកទីមួយនេះ វានឹងអាចនាំឱ្យមានកំហុសប្រាសចាក ហើយមានការជំទាស់”) (និយាយទៅកាន់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី); ឯកសារលេខ **E1/34.1** ប្រតិចារឹក, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ត្រង់ទំព័រ ១៥ បន្ទាត់ ១៥-១៩ (ប្រធានអង្គជំនុំជម្រះ៖ “ពិនិត្យមើលអំពីព្រឹត្តិការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ បំបែកយកមកធ្វើសវនាការនៅដំណាក់កាលដំបូង ដូចមានចែងកំណត់នៅក្នុងឯកសារ E124/7.2។ នេះជាវិសាលភាពនៃអង្គហេតុដែលភាគីអាចពិនិត្យសិក្សាស្វែងយល់នៅក្នុងសំណុំរឿងប្រវត្តិភ័ស្តុតាងដែលខ្លួយល់ឃើញថា មានការពាក់ព័ន្ធទៅនឹងព្រឹត្តិហេតុពាក់ព័ន្ធទៅនឹងអង្គហេតុដែលកំណត់នៅក្នុងវិសាលភាពនៅក្នុងឯកសារនេះ ដែលយើងហៅឈ្មោះម្យ៉ាងទៀតថា “សំណុំរឿង ០០២/០១”) (និយាយទៅកាន់មេធាវីការពារក្ដី);

ការសម្រេចលើវិសាលភាពនៃភស្តុតាងជាឯកសារ ដែលត្រូវទទួលយក[100] ហើយក៏បានប្រើប្រាស់នូវអំណាចបែបនេះក្នុងពេលសវនាការរហូតមក[101]។ ជាចុងក្រោយ ការសម្រេចទៅលើការពង្រីក

ឯកសារលេខ **E1/52.1** ប្រតិចារឹក, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ត្រង់ទំព័រ ១៨-១៩ បន្ទាត់ ២២-២៥, ១-៥ (ប្រធានអង្គជំនុំជម្រះ៖ "លោកតំណាងសហព្រះរាជអាជ្ញាជាតិ សូមលោកគិតឡើងវិញ ហើយផ្ដល់នូវការសួរដេញដោលឲ្យស្របទៅនឹងឯកសារ E124/2.2 ដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការ សម្រាប់ដំណាក់កាលដំបូងនៃកិច្ចដំណើរការសវនាការ ដែលពាក់ព័ន្ធទីមួយ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ពីកថាខណ្ឌ ១៨ ដល់ ៣២ ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលដែលមានពាក់ព័ន្ធនឹងបក្សកុម្មុយនីស្តកម្ពុជា ក្រោយឆ្នាំ ១៩៧៥ គណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការអចិន្ត្រៃយ៍ មន្ទីរ៨៧០ រចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន ហើយនឹងតួនាទីមុខងាររបស់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ហើយនិងទំនាក់ទំនងការងារ"); ឯកសារលេខ **E1/64.1** ប្រតិចារឹក, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ត្រង់ទំព័រ ១០ បន្ទាត់ ១៨-២០ (ប្រធានអង្គជំនុំជម្រះ៖ "តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បើសិនជាមានសំណួរផ្សេងគឺអាចសួរបន្តទៀតបាន ហើយសូមខិតខំបញ្ចូលមកក្នុងស្ថានភាពដែលភាពពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយមានបង្ហាញជាក់ច្បាស់នៅក្នុងដីកាដំណោះស្រាយ ដែលបានកំណត់យកមកធ្វើសក្ខីកម្មនៅក្នុងសំណុំរឿងកម្រិតវិសាលភាពសំណុំរឿង ០០២/០១"); ឯកសារលេខ **E1/135.1** ប្រតិចារឹក, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ត្រង់ ទំព័រ ១១២ បន្ទាត់ ១៧-២១ (ប្រធានអង្គជំនុំជម្រះ៖ "តំណាងសហព្រះរាជអាជ្ញា សូមរៀបចំនូវការតាំងសំណួររបស់លោក ឲ្យក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ជាការសមស្រប ពីព្រោះយើងកំណត់ធ្វើសវនាការនេះតែសំណុំរឿង០០២/០១ គឺជម្លៀសលើកទី១ និងទី២ ទេ។ ហើយអម្បាញ់មិញនេះគឺវាជាផលវិបាកនៃការជម្លៀសលើកទី៣ហើយ។ ហើយអង្គហេតុដែលពាក់ព័ន្ធនៅខេត្តពោធិ៍សាត់ គឺអង្គហេតុនៃទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃតែមួយគត់"); ឯកសារលេខ **E1/100.1** ប្រតិចារឹក, ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ត្រង់ទំព័រ៨៣ បន្ទាត់ ៦-៨ (ប្រធានអង្គជំនុំជម្រះ៖ "សំណួរនេះពិតជាសំណួរមិនពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ចំពោះជនជាប់ចោទដែលមាននៅក្នុងដីកាដំណោះស្រាយ។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ!") (និយាយទៅកាន់មេធាវីការពារក្ដី); ឯកសារលេខ **E1/108.1** ប្រតិចារឹក, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ ត្រង់ទំព័រ៣៣-៣៥ បន្ទាត់ ១៨-២៥, ១-២ (ប្រធានអង្គជំនុំជម្រះ៖ "សំណួរអម្បាញ់មិញលោកមិនសួរពាក់ព័ន្ធជាមួយអត្តចរិតជនជាប់ចោទទេ គឺសួរពាក់ព័ន្ធជាមួយនឹងបុគ្គលផ្សេងទៀត ដែលមិនពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយដែលមានខ្លឹមសារចោទប្រកាន់ ឬក៏ដោះបន្ទុកនៅក្នុងរឿងក្ដីនេះទេ។ យើងមិនហាមឃាត់លោកទេ ប៉ុន្តែសំណួររបស់លោកឃើញថា ចេញឆ្ងាយពីវិសាលភាពនៃដីកាដំណោះស្រាយ។ សំណួររបស់លោកតាំងពីដើមទីរហូតដល់ពេលនេះ គឺពាក់ព័ន្ធតែជាមួយបុគ្គលម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ដែលក្រៅនៅក្នុងសំណុំរឿងនេះ") (និយាយទៅកាន់មេធាវីការពារក្ដី); ឯកសារលេខ **E1/126.1** ប្រតិចារឹក, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ត្រង់ទំព័រ ៤ បន្ទាត់ ២-៧ (ប្រធានអង្គជំនុំជម្រះ៖ "អង្គជំនុំជម្រះបានធ្វើច្រើនដែរហើយ ចំពោះសាក្សីដែលភាគីហ្នឹង គឺអាចសួរនៅក្នុងក្របខណ្ឌវិសាលភាពទូលំទូលាយក្នុងសំណុំរឿង០០២ ទាំងបានក្នុងករណីមួយចំនួន ហើយសាក្សីទាំងនោះសុទ្ធតែអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីជាមុន។ សាក្សីណាដែលអង្គជំនុះជម្រះមិនបានជូនដំណឹងជាមុន អំពីក្របខណ្ឌវិសាលភាពធំទូលំទូលាយដូចនេះទេ គឺសូមអង្គជំនុំជម្រះកំហិតកំណត់ការពិភាក្សាដេញដោលសាក្សីទៅតាមក្របខណ្ឌនៃអង្គហេតុចាំបាច់ដែលកំណត់យកមកធ្វើការពិភាក្សាដេញដោល") (និយាយទៅកាន់មេធាវីការពារក្ដី)។

[100] វិធាន ៨៧(៣) និង(៤) នៃវិធានផ្ទៃក្នុង។

វិសាលភាពដោយមានការកំណត់ក្នុងពេលថ្មីៗនេះ ដោយការដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃនោះ គឺអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់នូវអំណាចរបស់ខ្លួន ក្នុងការកម្រិតកំណត់វិសាលភាពនៃការពង្រីកវិសាលភាពតែត្រឹមការសម្លាប់ "ដែលកើតឡើងភ្លាមៗក្រោយការជម្លៀសចេញពីទីក្រុងភ្នំពេញ... ប៉ុន្តែមិនពង្រីកទៅដល់ការសម្លាប់ដែលកើតឡើងចន្លោះឆ្នាំ១៩៧៦ និង១៩៧៧ទេ"[102]។ យោងទៅតាមការពិចារណាទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងពិតជាមានកំហុសយ៉ាងច្បាស់ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចថា "ភាពស្មុគស្មាញដែលរំពឹងទុកជាមុន" សម្រាប់ការកម្រិតកំណត់វិសាលភាពដែលបានស្នើឡើង អាចនឹងមានហានិភ័យដល់ការពន្យាពេលយ៉ាងយូរដល់សវនាការ។

៥៦- បន្ថែមពីលើនេះទៀត មិនមានភាពច្បាស់លាស់ថាតើភាពស្មុគស្មាញដែលបានរំពឹងទុកដោយមិនជាក់លាក់នោះ នឹងមានផលប៉ះពាល់បែបណា (ប្រសិនបើមាន) ក្នុងការដាក់បញ្ចូលមន្ទីរស-២១ និងទីតាំងសម្លាប់មនុស្សក្នុងស្រុក១២ ទៅក្នុងសំណុំរឿង០០២/០១។ តាមការស្មាន ភាពស្មុគស្មាញនានាដែលអាចកើតឡើងចំពោះសំណុំរឿង០០២/០១ អាចអនុវត្តផងដែរចំពោះសវនាការបន្តបន្ទាប់ដែលលើក

[101] សូមមើលឧទាហរណ៍ ឯកសារលេខ **E223/2** សវនាការដេញដោលលើឯកសារពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223), ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៩ ("ដើម្បីអនុញ្ញាតឲ្យមានការជំទាស់តទល់ប្រកបដោយប្រសិទ្ធភាពទៅនឹងចម្លើយទាំងនេះ អនុលោមតាមសេចក្តីណែនាំមុនៗរបស់ខ្លួន និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងសេចក្តីសម្រេច E96/17, អង្គជំនុំជម្រះសូមជូនដំណឹងទៅសហព្រះរាជអាជ្ញាថា មានតែចម្លើយទាំងឡាយណាដែលអាចមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមថ្ងៃ សុក្រទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ប៉ុណ្ណោះដែលអាចស្នើសុំដាក់ជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ"); ឯកសារលេខ **E96/7** សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ១៧, ៣៥ ("អនុលោមតាមក្របខណ្ឌនេះ អង្គជំនុំជម្រះនឹងផ្តោតទៅលើលក្ខណៈវិនិច្ឆ័យអំពីភាពអាចទទួលយកបាននៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដើម្បីធ្វើការសម្រេចថាតើ កំណត់ហេតុស្តាប់ចម្លើយ (រួមទាំងឧបសម្ព័ន្ធ) ឬប្រតិចារឹកទាំងឡាយដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយពុំមានការតទល់នៅក្នុងសវនាការនោះ "ត្រូវបានច្បាប់អនុញ្ញាត" ដែរឬទេ ហើយស្ថិតនៅក្រោមលក្ខខណ្ឌមួយណា (វិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង)")។ ឯកសារលេខ **E190** សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ១ ("សេចក្តីសម្រេចនេះកំណត់អំពីលក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញ និងដំណើរការនីតិវិធីសម្រាប់ដាក់ឯកសារថ្មីៗ (*មានន័យថា* ឯកសារទាំងឡាយដែលដាក់ក្រោយពេលសវនាការបានចាប់ផ្តើម) នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាននេះ")។

[102] ឯកសារលេខ **E163/5**, សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣។

យកទីតាំងឧក្រិដ្ឋកម្មទាំងអស់នេះមកដោះស្រាយ។ ការដាក់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មក្នុងពេលឥឡូវនេះ នឹងជំរុញទៅមុខនូវភារកិច្ចក្នុងការដោះស្រាយជាមួយភាពស្មុគស្មាញទាំងអស់នេះ ហើយជួយជំរុញដល់ប្រសិទ្ធភាពតុលាការ និងភាពច្បាស់លាស់ផ្លូវច្បាប់។

៥៧- ទោះជាក្នុងហេតុការណ៍ណាក៏ដោយ សហព្រះរាជអាជ្ញាសូមលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងបានបំផ្លើសការប្រឈមនានា ក្នុងការគ្រប់គ្រងលើការពង្រីកវិសាលភាពដែលបានស្នើឡើង ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាទៅលើសិទ្ធិអំណាចដ៏សំខាន់របស់ខ្លួន ក្នុងការគ្រប់គ្រងដំណើរការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងមានប្រសិទ្ធភាពនោះទេ។ កំហុសនេះមានលក្ខណៈច្បាស់លាស់ជាពិសេស នៅពេលដែលគិតដល់វិសាលភាពនៃភស្តុតាងដែលមានចំនួនកំណត់ តម្រូវឱ្យមានការជំនុំជម្រះ ដែលជាផ្នែកនៃការពង្រីកវិសាលភាពទាំងនេះ (ដូចមានរៀបរាប់ក្នុងផ្នែក (iii) ខាងក្រោម) ។

### *iii. ការខកខានមិនបានវាយតម្លៃឱ្យបានត្រឹមត្រូវនូវចំនួនសាក្សីដែលតម្រូវឱ្យស្តាប់សក្ខីកម្ម ពាក់ព័ន្ធនឹងមន្ទីរស-២១ និងស្រុក១២*

៥៨- នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ចំនួនសាក្សីដែលបានស្នើសុំកោះហៅដោយភាគីនានា ទាក់ទិននឹងមន្ទីរស-២១ និងស្រុក១២ នឹងអាចធ្វើឱ្យសវនាការលើសំណុំរឿង00២/0១ អូសបន្លាយពេលយូរ[103]។

៥៩- អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលអាចវិនិច្ឆ័យបាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយផ្អែកសំអាងហេតុរបស់ខ្លួនទៅលើការពិចារណាមួយដែលពុំមានការពាក់ព័ន្ធ (ចំនួនសាក្សីដែលត្រូវបាន *ស្នើឡើង*) និងខកខានពុំបានពិចារណា និងសម្រេចឱ្យបានត្រឹមត្រូវទៅលើចំនួនសាក្សីដែលតម្រូវឱ្យចូលមកផ្តល់សក្ខីកម្ម។ ផ្នែកនៃបណ្តឹងសាទុក្ខនេះ នឹងបង្ហាញថាសវនាការបង្ហាញភស្តុតាង ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មដែលបានស្នើឡើងទាំងពីរនេះ នឹងតម្រូវឱ្យមានការពង្រីករយៈពេលនៃសវនាការទាំងមូលតិចតួចណាស់។

៦០- សហព្រះរាជអាជ្ញាបានស្វែងរកការកោះហៅសាក្សីសរុបចំនួន១១នាក់ សម្រាប់ទីតាំងទាំងពីរនោះ៖ ប្រាំមួយនាក់ពាក់ព័ន្ធនឹងស្រុក១២[104] និងប្រាំនាក់ពាក់ព័ន្ធនឹងមន្ទីរស-២១[105]។ សហព្រះរាជអាជ្ញាប៉ាន់

---

[103] ឯកសារលេខ **E163/5** ដដែលដូចលើយោងខាងលើ ត្រង់កថាខណ្ឌ២។

[104] TCW-368, TCW-162, TCW-160, TCW-422, TCW-651 និង TCW-298 ។ ឯកសារលេខ **E218/2**, សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១២, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២, ឧបសម្ព័ន្ធសម្ងាត់ ក។

[105] TCW-281, TCW-698, TCW-540, TCCP-21 និងTCW-232 ឯកសារលេខ **E218/2** ដដែលដូចលើយោងខាងលើ។

ប្រមាណថា ភ័ស្តុតាងនេះអាចត្រូវបានធ្វើក្នុងរយៈពេលប្រហែល១៦ថ្ងៃ[106]។ ការប៉ាន់ប្រមាណនេះគឺស៊ីសង្វាក់គ្នាជាមួយនឹងសេចក្តីណែនាំថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុលោមតាមសេចក្តីណែនាំនេះ គេទុកពេលឲ្យតែរយៈពេលមួយថ្ងៃប៉ុណ្ណោះសម្រាប់មេធាវីការពារក្តីទាំងអស់ សួរដេញដោលសាក្សី (ឬដើមបណ្តឹងរដ្ឋប្បវេណី) អំពីទីតាំងឧក្រិដ្ឋកម្ម[107]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អៀង សារី និង ខៀវ សំផន ពុំបានស្វែងរកការស្តាប់សក្ខីកម្មសាក្សីបន្ថែមណាទៀតឡើយ ទាក់ទិននឹងទីតាំងទាំងពីរនេះ។

៦១- មេធាវីការពារក្តី នួន ជា ពុំបានស្នើឡើងនូវសាក្សីណាម្នាក់ឡើយ ទាក់ទិននឹងស្រុក១២។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់បានស្នើសុំសាក្សីចំនួន៣១នាក់[108] ឲ្យមកផ្តល់សក្ខីកម្មទាក់ទិននឹងមន្ទីរស-២១ ដោយមានបួននាក់ក្នុងចំណោមអ្នកទាំងនោះ ក៏ត្រូវបានស្នើឡើងផងដែរ ដោយសហព្រះរាជអាជ្ញា[109]។ សាក្សីនៅសល់២៧នាក់ទៀត (ម្នាក់ក្នុងចំណោមអ្នកទាំងនោះអាចស្លាប់ហើយ)[110] រួមបញ្ចូលនូវបុគ្គលជាច្រើនដែលទំនងជាពុំមានការជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១ ឬបើពុំដូច្នោះទេ សក្ខីកម្មនៅក្នុងតុលាការរបស់អ្នកទាំងនោះពុំមានភាពចាំបាច់ឡើយ។

៦២- មេធាវីការពារក្តី នួន ជា ពុំបានផ្តល់នូវយុត្តិកម្មឲ្យបានច្បាស់លាស់ ដើម្បីគាំទ្រសាក្សីដែលខ្លួនបានស្នើឡើងនោះឡើយ[111]។ ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគជាមូលដ្ឋានលើសំណើរបស់ពួកគាត់នឹង

---

[106] ឯកសារលេខ **E218/2** ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ ១៦។

[107] សេចក្តីណែនាំទាំងនេះត្រូវបានចេញតាមរយៈសារអេឡិកត្រូនិចពីមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង និងត្រូវបានបញ្ជាក់នៅក្នុងសេចក្តីណែនាំនៅពេលចាប់ផ្តើមសួរដេញដោល៖ សូមមើលឧទាហរណ៍ ឯកសារលេខ **E1/136.1** ប្រតិចារឹក, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២, ត្រង់ទំព័រ ៣១ បន្ទាត់៨-១៤; ឯកសារលេខ **E1/137.1** ប្រតិចារឹក, ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០១២, ត្រង់ទំព័រ ៥ បន្ទាត់ ១៧-២២។

[108] TCW-49, TCW-53, TCW-115, TCW-88, TCW-118, TCW-125, TCW-140, TCW-232, TCW-290, TCW-316, TCW-348, TCW-367, TCW-379, TCW-405, TCW-410, TCW-441, TCW-470, TCW-474, TCW-479, TCW-491, TCW-499, TCW-512, TCW-523, TCW-540, TCW-598, TCW-632, TCW-655, TCW-698, TCCP-21, TCCP-22 និង TCCP-93។ សូមមើល ឯកសារលេខ **E236** បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៧ ។

[109] TCW-540, TCW-698, TCW-232 និង TCCP-21។

[110] TCW-499។ សូមមើល ឯកសារលេខ **E236** បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៧ ឧបសម្ពន្ធ **II** ។

[111] សូមមើលការសង្ខេបចម្លើយសាក្សី ដូចមាននៅក្នុង**ឧបសម្ព័ន្ធ II**។

បង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់កោះហៅបុគ្គលភាគច្រើនក្នុងចំណោមបុគ្គលទាំងនោះឲ្យមកផ្តល់សក្ខីកម្មឡើយ។

៦៣- ទីមួយ សាក្សីជាច្រើនក្នុងចំណោមសាក្សីដែលត្រូវបានស្នើឡើងដែលមេធាវីការពារក្តី នួន ជា បានពិពណ៌នាថាជាអតីតអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ ទំនងជាពុំមានការជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១ ឡើយ៖

ក) នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ពុំមានភ័ស្តុតាងពិតប្រាកដ" ដើម្បីគាំទ្រដល់ការចោទប្រកាន់ថា TCW-523 ត្រូវបានជាប់ឃុំឃាំង ត្រូវបានធ្វើទារុណកម្ម ឬត្រូវបានសួរចម្លើយនៅមន្ទីរស-២១ ឡើយ[112]។

ខ) ទាក់ទិនទៅនឹង TCW-379 អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទោះបីជាអង្គជំនុំជម្រះពុំមានការសង្ស័យថាសាក្សី "បានទទួលរងគ្រោះយ៉ាងខ្លាំង ដោយសារតែការឃុំខ្លួន ការសួរចម្លើយ និងការធ្វើទារុណកម្មក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មិនមានភ័ស្តុតាងបង្ហាញ ថាការរងគ្រោះនោះកើតឡើងនៅមន្ទីរស-២១ ទេ"[113]។

គ) អង្គជំនុំជម្រះសាលាដំបូងសម្រេចថា មានចម្ងល់ថាតើ TCW-405 បានជាប់ឃុំឃាំងនៅមន្ទីរស-២១ ឬយ៉ាងណា[114]។

ឃ) យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់គាត់ TCW-441 បានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខសង់ មិនមែននៅមន្ទីរស-២១ ទេ[115]។

៦៤- ទីពីរ មេធាវីការពារក្តីស្វែងរកការកោះហៅវេជ្ជបណ្ឌិតផ្នែកចិត្តវិទ្យាពីររូបដែលបានផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង០០១ ដើម្បីមកផ្តល់ភ័ស្តុតាងលើបញ្ហានានាដូចជា "ការជំនុំជម្រះប្រកបដោយយុត្តិធម៌" "ការស៊ើបសួររបស់ក.ស.ច.ស" "សក្ខីកម្មរបស់ឌុច" និង "ភាពអាចជឿទុកចិត្តបានរបស់ឌុច"[116]។

---

[112] ឯកសារលេខ **E188** សាលក្រមលើសំណុំរឿង០០១, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ត្រង់កថាខណ្ឌ៦៤៧។

[113] ឯកសារលេខ **E188** ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ ៦៤៧។

[114] ឯកសារលេខ **E188** ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ ៦៤៧។

[115] ឯកសារលេខ **D25/1** កំណត់ហេតុលាយលក្ខណ៍នៃការស្តាប់ចម្លើយសាក្សី, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ទំព័រ៣ និង ឯកសារលេខ **D390** ដីកាស្តាពរ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ត្រង់កថាខណ្ឌ ៤៩៤។

[116] TCW-655 and TCW-290. See ឯកសារលេខ **E236** បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៧ និង **ឧបសម្ព័ន្ធ II**។

ពិតណាស់ បញ្ហាទាំងនេះមិនមែនជាបញ្ហាដែលយោបល់របស់វេជ្ជបណ្ឌិតផ្នែកចិត្តវិទ្យា អាចជួយដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ជាក់ការពិតទាក់ទិននឹងមន្ទីរស-២១ នោះទេ។

៦៥- ទីបី មេធាវីការពារក្តី នួន ជា ស្នើសុំឲ្យកោះហៅសាក្សីជាច្រើន ដែលភ័ស្តុតាងរបស់អ្នកទាំងនោះមានភាពច្រំដែលជាច្រើន។ យោងតាមសេចក្តីសង្ខេបផ្ទាល់ខ្លួនរបស់មេធាវីការពារក្តី សាក្សីលើសពីពាក់កណ្តាលដែលមេធាវីការពារក្តីបានស្នើសុំ គឺជាអតីតបុគ្គលិកនៅមន្ទីរស-២១[117]។ មេធាវីការពារក្តី មិនបានផ្តល់ព័ត៌មានថាតើហេតុអ្វីបានជាសាក្សីទាំងអស់នេះមានសារៈសំខាន់ ឬថាតើហេតុអ្វីបានជារាល់សាក្សីទាំងអស់នេះ អាចផ្តល់សក្ខីកម្មចំពោះបញ្ហាសំខាន់ ករណី ដូចជាទំនាក់ទំនងរវាងមន្ទីរស-២១ និង នួន ជា ជាដើម។

៦៦- សហព្រះរាជអាជ្ញាគាំទ្រសិទ្ធិរបស់ នួន ជា ក្នុងការកោះហៅសាក្សីក្នុងចំនួនមួយសមហេតុផលដែលសាក្សីទាំងនោះ បានដឹងដោយផ្ទាល់អំពីមន្ទីរស-២១ ដើម្បីតវ៉ាចំពោះភ័ស្តុតាងដែលទាក់ទងនឹងមន្ទីរសន្តិសុខ (ឬការចូលរួមរបស់ជនជាប់ចោទនៅមន្ទីរសន្តិសុខនោះ ប្រសិនបើមានពាក់ព័ន្ធ)។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីទទួលបន្ទុកក្នុងការបង្ហាញថា ភ័ស្តុតាងនោះមានភាពពាក់ព័ន្ធ និងមិនច្រំដែល។ ការលើកឡើងនូវពាក្យទូទៅ ដូចជា "មន្ទីរស-២១" "ភាពអាចជឿទុកចិត្តបានរបស់ឌុច" ឬ "ការស្នើសុំឲ្យបញ្ជាក់ច្បាស់ចំពោះសក្ខីកម្មរបស់ ឌុច" គឺមិនគ្រប់គ្រាន់នោះទេ[118]។ អង្គជំនុំជម្រះមានតួនាទីឯករាជ្យដើម្បីធានាថា ការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់រហ័ស ដោយរួមបញ្ចូលទាំងការអនុញ្ញាតឲ្យបង្ហាញនូវភ័ស្តុតាងដែលអាចនាំឲ្យបញ្ជាក់ការពិត និងបដិសេធមិនបញ្ចូលភ័ស្តុតាងដែលមានភាពច្រំដែល មិនពាក់ព័ន្ធ ឬមិនសមស្រប ក្នុងការបង្ហាញអំពីអង្គហេតុដែលខ្លួនអះអាងថាចង់បង្ហាញ[119]។ និយាយក្នុងន័យចង្អៀត សាក្សីជាច្រើនដែលភាគីនានាស្នើសុំឲ្យកោះហៅ គឺមិនមានភាពពាក់ព័ន្ធទាល់តែសោះ ប្រសិនបើអង្គជំនុំជម្រះបំពេញតួនាទីរបស់ខ្លួនត្រឹមត្រូវ និងអនុលោមតាមច្បាប់។

[117] TCW-88, TCW-698, TCW-632, TCW-598, TCW-540, TCW-53, TCW-512, TCW-499, TCW-491, TCW-474, TCW-470, TCW-410, TCW-367, TCW-348, TCW-316, TCW-232 and TCW-125. សូមមើល ឯកសារលេខ **E236** បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៧ និង **ឧបសម្ព័ន្ធ II**។

[118] សូមមើល **ឧបសម្ព័ន្ធ II**។

[119] វិធាន ៨៧ នៃវិធានផ្ទៃក្នុង; មាត្រា ៣១៨ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

៦៧- ដោយសារតែបច្ច័យនៃទឡ្ហីករណ៍នេះ អង្គជំនុំជម្រះសាលាដំបូងក៏មានអំណាចរបស់ខ្លួន ដើម្បីសម្រេចលើសាក្សីក្នុងចំនួនមួយដែលសមហេតុផល ដើម្បីស្តាប់*សក្ខីកម្មផ្ទាល់មាត់* និងទទួលយកភ័ស្តុតាងបន្ថែមតាមវិធីនៃការផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់។ ករណីនេះគឺស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការប្រើប្រាស់ចម្លើយសាក្សី និងប្រតិចារឹក ដែលមិនបានបង្ហាញអំពីអំពើ ឬអាកប្បកិរិយារបស់ជនជាប់ចោទ[120]។ ដូចដែលអង្គជំនុំជម្រះបានសម្រេច ពុំមានសិទ្ធិវិជ្ជមានឡើយ ទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិសម្រាប់ជនជាប់ចោទ ក្នុងការពិនិត្យមើលលើ*រាល់*សាក្សីពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម ដែលចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីទាំងនោះ ត្រូវបានដាក់បញ្ចូលជាភ័ស្តុតាង[121]។ ចម្លើយជាលាយលក្ខណ៍អក្សរដែលមានភាគច្រើន ពាក់ព័ន្ធនឹងដំណើរការខាងក្នុងរបស់មន្ទីរស-២១ មិនបានលើកឡើងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ។

៦៨- ទោះបីជា នួន ជា មានសិទ្ធិលើកសំណើសមហេតុផល ដើម្បីស្នើសុំឲ្យកោះហៅសាក្សីមួយចំនួនតូចដើម្បីស្តាប់សក្ខីកម្មក៏ដោយ ក៏ការស្នើសុំឥតបានការដើម្បីស្តាប់សក្ខីកម្មសាក្សីជាច្រើនរបស់គាត់ដែលពាក់ព័ន្ធត្រូវបានរៀបរាប់មិនច្បាស់លាស់ មិនអាចយកជាមូលដ្ឋានស្របច្បាប់ ដើម្បីសន្និដ្ឋានថាដំណើរការនីតិវិធីដែលទាក់ទងនឹងមន្ទីរស-២១ អាចធ្វើឲ្យសវនាការអូសបន្លាយពេលយូរនោះទេ។ អង្គជំនុំជម្រះសាលាដំបូងភ័ន្តច្រឡំក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានផ្តល់នូវការវិភាគណាមួយនៃភ័ស្តុតាងសក្ខីកម្មដែលស្នើឡើងឡើយ និងផ្អែកលើការពិចារណាដែលមិនពាក់ព័ន្ធ ក្នុងការសន្និដ្ឋានអំពីការពន្យារពេលសវនាការ។

### *iv. ការខកខានក្នុងការវាយតម្លៃឲ្យបានត្រឹមត្រូវនូវទំនាក់ទំនង និងលំដាប់លំដោយបន្តបន្ទាប់ រវាងវិសាលភាពសវនាការបច្ចុប្បន្ន និងមន្ទីរស-២១ និងទីតាំងសម្លាប់មនុស្សស្រុក១២*

៦៩- ក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងថ្លែងថា "អង្គជំនុំជម្រះសាលាដំបូងនៅតែយល់ឃើញថា ទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំងនេះ មិនជាប់ពាក់ព័ន្ធជិតស្និទ្ធទៅនឹងការចោទប្រកាន់ចំពោះអង្គហេតុក្នុងសំណុំរឿង០០២/០១ ឬថាការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងនេះ មិនសមស្រប

[120] ឯកសារលេខ **E96/7**, សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ១៧-២៥។

[121] ឯកសារលេខ **E96/7**, ដដែលដូចលើកយោងខាងលើ ត្រង់កថាខណ្ឌ ២១-២៥។

តាមលំដាប់លំដោយត្រឹមត្រូវនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១”[122] នោះទេ។ ដោយសារថា អង្គហេតុទាំងនោះបានទទួលយករួចហើយថា *ស្ថិត*នៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ព្រមទាំង លក្ខណៈ និងទំហំនៃភស្តុតាងដែលត្រូវបានលើកមកបង្ហាញមកដល់ពេលនេះ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ គឺមិនត្រឹមត្រូវទៅតាមភាពជាក់ស្តែងលើអង្គហេតុឡើយ និងនេះជាកំហុសមួយដែលអាចមើលឃើញនៅក្នុងការអនុវត្តឆន្ទានុសិទ្ធរបស់ខ្លួន។ នេះគឺជាសេចក្តីសម្រេចមួយដែលអ្នកជំនុំជំម្រះលើអង្គហេតុដោយមិនមានហេតុផល ហើយបានទទួលដំណឹងអំពីភស្តុតាងទាំងអស់ដែលពេលនេះ ដាក់នៅចំពោះមុខអង្គជំនុំជម្រះ អាចឈានដល់បាន។

៧០- ដូចដែលមានចែងនៅក្នុងផ្នែកប្រវត្តិនីតិវិធីសំណុំរឿង០០២/០១ រួមបញ្ចូលការពិនិត្យមើលលើប្រធានបទធំៗជាច្រើនដែលមាននៅក្នុងសំណុំរឿង០០២ រួមទាំងផ្នែកប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធរដ្ឋអំណាច និងការប្រាស្រ័យទាក់ទងរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ តួនាទី និងឋានៈរបស់ជនជាប់ចោទព្រមទាំងការអភិវឌ្ឍន៍គោលនយោបាយឧក្រិដ្ឋទាំងប្រាំ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[123]។ នៅក្នុងដំណើរការជំនុំជម្រះចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់នូវភស្តុតាងដែលមានចំនួនដ៏ច្រើនពាក់ព័ន្ធនឹងប្រធានបទទាំងនេះ។ ដូចដែលមានបង្ហាញក្នុងកថាខណ្ឌ៧៧-៨០ខាងក្រោម ភាគច្រើននៃភស្តុតាងទាំងនេះបង្ហាញដោយផ្ទាល់ពីការអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីកម្ទេចខ្មាំងដែលខ្លួនបានសន្មតរួមទាំងមន្ទីរស-២១។

៧១- ព្រឹត្តការណ៍ជាមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលបច្ចុប្បន្ននេះស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ គឺ (i) ការជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញ (ដែលជាផ្នែកនៃគោលនយោបាយទូទៅនៃការជម្លៀសប្រជាជនកម្ពុជាពីទីក្រុងនានា ក្នុងខែមេសា ឆ្នាំ១៩៧៥ (ii) ការសម្លាប់ទ្រង់ទ្រាយធំនៅទួលពោធិ៍ជ្រៃភ្លាមៗ បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ និង (iii) ការជម្លៀសប្រជាជនស៊ីវិលដោយបង្ខំលើកទីពីរ

[122] ឯកសារ E163/5 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

[123] ឯកសារ E124/7.1/កែតម្រូវ-១ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការជំនុំជម្រះដំណាក់កាលទីមួយនៃសំណុំរឿង០០២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ (បញ្ជីកថាខណ្ឌពាក់ព័ន្ធដើម) ត្រង់កថាខណ្ឌ១ និង៣។ ឯកសារ E124/7.3 បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿងលេខ០០២/០១ ការដែលបានធ្វើវិសោធនកម្មបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមដែលឋិតក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ០០២/០១(E163) ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ២។

ដែលត្រូវបានចាប់ផ្តើមនៅចុងឆ្នាំ១៩៧៥[124]។ ព្រឹត្តិការណ៍ឧក្រិដ្ឋទាំងពីរដំបូងនេះមានពាក់ព័ន្ធដោយផ្ទាល់ និងមិនអាចប្រកែកបានទៅនឹងគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកម្ទេចខ្មាំងដែលខ្លួនបានសន្មត ដែលគោលនយោបាយនេះត្រូវបានអនុវត្តនៅមន្ទីរស-២១ និងការសម្លាប់នៅស្រុក១២។

៧២- គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក និងកម្ទេចខ្មាំងរបស់ខ្លួន គឺជាកត្តាចំបងនៃសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងនានាដោយបង្ខំ នៅក្នុងខែមេសា ឆ្នាំ១៩៧៥[125]។ ការជម្លៀសពីទីក្រុងទាំងនេះត្រូវបានរៀបចំឡើងដើម្បីបង្ក្រាបវណ្ណៈទីក្រុងនានាដែលបក្សចាត់ទុកវណ្ណៈទាំងនេះថាជាខ្មាំងពិតប្រាកដរបស់ខ្លួន និងដើម្បីកំណត់អត្តសញ្ញាណ និងកម្ទេចសមាសភាពដែលគ្រោះថ្នាក់បំផុតនៅក្នុងស្រទាប់វណ្ណៈទាំងនេះ[126]។ នេះគឺជាសកម្មភាពដំបូងនៃការអនុវត្តគោលនយោបាយមួយដែលនឹងត្រូវបានបន្តដោយមិនមានការរាំងស្ទះ តាមរយៈការបង្កើតមន្ទីរសន្តិសុខនានាដូចជា មន្ទីរស-២១ ភ្លាមៗក្រោយពីការជម្លៀស។ ទោះជានៅអំឡុងពេលជម្លៀសក្តីខ្មាំងដែលត្រូវបានសន្មត ដូចជាសមាជិកនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានដួលរលំ ត្រូវបានដកចេញពីចំណោមមហាជន និងត្រូវបានសម្លាប់ភ្លាមៗដោយយោធាខ្មែរក្រហម[127]។ ការសម្លាប់នៅទួលពោធិ៍ជ្រៃដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ហើយនាពេលនេះ គឺជាផ្នែកមួយនៃដំណើរការនេះ។

៧៣- ដោយមានការបញ្ចូលទីតាំងទួលពោធិ៍ជ្រៃ មានការពិបាកក្នុងការយល់ពីការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងដោយមិនព្រមបញ្ចូលព្រឹត្តិការណ៍នៅស្រុក១២ ទៅនឹងការចោទប្រកាន់លើអង្គហេតុនៅ

[124] ឯកសារ E124/7.3 បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដែលត្រូវបានកែតម្រូវបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០១ (E163) ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ២។

[125] ដោយមានការគាំទ្រនៅក្នុងផ្នែកសំអាងហេតុនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត: ឯកសារ D427 ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ២៤៨។

[126] ជាឧទាហរណ៍ សូមមើលឯកសារ D199/26.2.35 ប៉ុល ពត លើបញ្ហានៃការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ ត្រង់ ERN 00390921។ ឯកសារ **E3/745** ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ត្រង់ERN00401486, **E1/92.1** ប្រតិចារឹក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ត្រង់កថាខណ្ឌ ៦៩-៧០ និង៧៥-៧៦ និង៧៨-៧៩។

[127] ជាឧទាហរណ៍ សូមមើលភ័ស្តុតាងដែលមានយោងនៅក្នុងដីកាដំណោះស្រាយ: ឯកសារ D427 ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ២៣៤-២៣៥។

ក្នុងសំណុំរឿង00២/0១ ដោយលើកឡើងថាព្រឹត្តិការណ៍នេះ "មិនពាក់ព័ន្ធជិតស្និទ្ធ"។ ឧក្រិដ្ឋកម្មដែលកើតមាននៅស្រុក១២ គឺបានកើតឡើងភ្លាមៗក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវបានអះអាងថាមានពាក់ព័ន្ធនឹងការសម្លាប់ទ្រង់ទ្រាយធំនៃ "ប្រជាជនថ្មី" ដែលពួកគេជាច្រើនរយនាក់ គឺជាអ្នកដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ[128]។ ការមិនដាក់បញ្ចូលទីតាំងនេះ *ជាពិសេស* នៅពេលដែលមានការដាក់បញ្ចូលទីតាំងទួលពោធិ៍ជ្រៃ (ដែលស្ថិតនៅក្នុងខេត្តពោធិ៍សាត់) គឺជាការបង្ហាញយ៉ាងច្បាស់ពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអធិប្បាយពីអង្គហេតុឲ្យបានត្រឹមត្រូវ ដើម្បីធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន។ ពិតណាស់ថាការសម្លាប់នៅស្រុក១២ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតទៅសំណុំរឿង00២/0១ ជាងការសម្លាប់នៅទួលពោធិ៍ជ្រៃ ដោយហេតុថាជនរងគ្រោះនៅទីតាំស្រុ១២ គឺជាជនភៀសខ្លួនមកពីទីក្រុងភ្នំពេញ និងមកពីទីប្រជុំជនផ្សេងៗ ចំណែកជនរងគ្រោះនៅទីតាំសម្លាប់ទួលពោធិ៍ជ្រៃ គឺជាមន្ត្រីរាជការ និងមន្ត្រីយោធារបស់របស់សាធារណរដ្ឋខ្មែរដែលត្រូវបានកោះហៅមកចូលរួមប្រជុំមួយនៅទីបញ្ជាការខេត្តពោធិ៍សាត់ ហើយបន្ទាប់មកត្រូវបានគេចាប់យកទៅសម្លាប់។

៧៤- ដូចដែលបានធ្វើការកត់សម្គាល់ខាងលើ មានទំនាក់ទំនងដែលភ្ជាប់ជាមួយរវាងមន្ទីរសន្តិសុខ ស-២១ និងការជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញ ហើយធ្វើការសម្លាប់នៅទីតាំងនានា ដូចជា ស្រុក១២ និងទួលពោធិ៍ជ្រៃ។ នៅក្នុងសំណើដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ចូលមន្ទីរស-២១ ទៅក្នុងសំណុំរឿង00២/0១ សហព្រះរាជអាជ្ញាបានស្នើឡើងថា៖ "សេចក្តីសម្រេចធ្វើការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញត្រូវបានធ្វើឡើងដោយសំអាងលើមូលដ្ឋានថា ដើម្បីបណ្តេញប្រជាជនចេញពីទីក្រុងនានា បក្សអាចមានលទ្ធភាពកំណត់អត្តសញ្ញាណ "ខ្មាំង" និងកម្ទេចខ្មាំងទាំងនោះនៅតាមមន្ទីរសន្តិសុខ និងតាំងសម្លាប់នានា"[129]។ ការកំណត់អត្តសញ្ញាណ និងការសម្លាប់អ្នកដែលគេសន្មតថាជាខ្មាំងទាំងនោះបានបន្តពេញរយៈពេល ដូចមានចែងក្នុងដីកាដំណោះស្រាយ។ ក្នុងបរិបទនេះ មន្ទីរស-២១ ត្រូវបានចោទប្រកាន់ថាជា "មន្ទីរសន្តិសុខដ៏សំខាន់" និងជាស្ថាប័នមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលមួយចំនួនក្នុងថ្នាក់ខ្ពស់បំផុតរបស់បក្ស[130]។ ជាពិសេស ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្នុងសំណុំរឿង00១ ជនរងគ្រោះនៃមន្ទីរស-២១ រួម

[128] ឯកសារ D427 ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២0១0 កថាខណ្ឌ ៦៩៣-៦៩៧។

[129] E163 សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមដែលឋិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ00២/0១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២0១២ ត្រង់កថាខណ្ឌ១0។

[130] E427 ដីកាដំណោះស្រាយ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២0១២ ត្រង់កថាខណ្ឌ ៤២១-៤២២។

បញ្ចូលទាំង "អតីតទាហាន និងនាយទាហាន លន់ នល់"[131] ដែលជាក្រុមមនុស្សដែលត្រូវបានកំណត់ជាមុខសញ្ញាក្នុងអំឡុងពេលជម្លៀសទីក្រុងភ្នំពេញ និងការប្រហារជីវិតនៅទួលពោធិ៍ជ្រៃ[132]។

៧៥- តាមរយៈការពិចារណាលើករណីទាំងនេះ ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា មន្ទីរស-២១ មិនមានទំនាក់ទំនងជិតស្និទ្ធទៅនឹងការចោទប្រកាន់អង្គហេតុក្នុងសំណុំរឿង០០២/០១ ឬថាការបញ្ចូលនូវអង្គហេតុទាំងនេះអាចមិនសមស្របតាមលំដាប់លំដោយនៃការជំនុំជម្រះ គឺជាកំហុសមួយយ៉ាងពិតប្រាកដ ក្នុងអង្គហេតុនេះ។

៧៦- សហព្រះរាជអាជ្ញាសូមបញ្ជាក់បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសថែមទៀតអំពីអង្គហេតុ ឬកំហុសយ៉ាងច្បាស់ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបានយកចិត្តទុកដាក់លើភ័ស្តុតាងដ៏ច្រើន ដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ និងដែលមានការពាក់ព័ន្ធទៅនឹងការប្រហារជីវិតមនុស្សនៅមន្ទីរស-២១ និងស្រុក១២។

៧៧- នៅក្នុងដំណើរការនីតិវិធីរហូតមកដល់ពេលនេះ តុលាការបានប្រើពេលវេលាដ៏ច្រើន សម្រាប់ធ្វើសវនាការស្តាប់ភ័ស្តុតាងអំពីការបង្កើត និងការអនុវត្តនយោបាយកម្ទេចខ្មាំងរបស់ បកក ក្នុងរយៈពេលនោះដែលមានចែងក្នុងដីកាដំណោះស្រាយ (អំឡុងពេលដែលបន្តយ៉ាងសមស្របហួសពីរយៈពេលនៃការជម្លៀសប្រជាជនដោយបង្ខំលើកទី១ និងលើកទី២)។ សហព្រះរាជអាជ្ញាបានផ្តល់ជូនគំរូភ័ស្តុតាងទាំងនេះ **ក្នុងឧបសម្ព័ន្ធ I**។ ក្នុងពេលធ្វើសក្ខីកម្ម សាក្សីមួយចំនួនដូចជា កាំង ហ្កេចអ៊ាវ ហៅ ឌុច, សាស្ត្រាចារ្យ David Chandler, ភី ភួន និង មាស វឿន បានបញ្ជាក់ពីអត្ថិភាពនៃនយោបាយកម្ទេចខ្មាំង និងការអនុវត្តនយោបាយនេះ។ ទាំង ឌុច និងសាស្ត្រាចារ្យ Chandler បានបញ្ជាក់ពីបេសកកម្មរបស់មន្ទីរស-២១ និងទំនាក់ទំនងរបស់មន្ទីរនេះជាមួយគណៈមជ្ឈិមនៃ បកក ដែលមានការចោទប្រកាន់ថាមានជនជាប់ចោទនៅក្នុងនោះផង[133]។ សាក្សីជាច្រើនដទៃទៀតបានបញ្ជាក់ពីការចាប់ខ្លួន និងការបាត់ខ្លួនអ្នកដែលគេចោទថាជាខ្មាំង ដែលត្រូវបានគេឃុំខ្លួន និងសម្លាប់នៅមន្ទីរស-២១ ឬនៅ

---

[131] E188 សាលក្រមរឿងសំណុំរឿង០០១ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ត្រង់កថាខណ្ឌ ១៤០។

[132] ដោយសារសេចក្តីសម្រេចដែលរងការជំទាស់នេះ ការអនុវត្តគោលនយោបាយប្រឆាំងនឹងអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរត្រូវស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។ E124/7.3 បញ្ជីរាយកថាខណ្ឌ និងផ្នែកមួយចំនួននៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដែលត្រូវបានវិសោធនកម្មបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ (E163) ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ១(vii)។

[133] សូមមើល **ឧបសម្ព័ន្ធ I** ទំព័រ១។

តាមតំបន់ផ្សេងទៀតក្នុងប្រទេស។ ដូចបានបញ្ជាក់នៅក្នុង**ឧបសម្ព័ន្ធ I** អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើសវនាការលើភ័ស្តុតាងអំពីការចូលរួមរបស់ជនជាប់ចោទ ក្នុងការអនុវត្តនយោបាយកម្ទេចខ្មាំងរបស់ បកក និងអំណាចរបស់ពួកគេទៅលើមន្ទីរស-២១។

៧៨- ជាចាំបាច់ គួរកត់សម្គាល់ថា ក្នុងពេលដែលតុលាការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលយកភ័ស្តុតាងពីសាក្សីលើបញ្ហាទាំងនេះ មេធាវីការពារក្តីក៏ត្រូវបានផ្តល់ឱកាសស្មើគ្នា ដើម្បីសួរដេញដោលលើភ័ស្តុតាង និងតាមពិត មេធាវីការពារក្តីបានប្រើនូវឱកាសទាំងនេះដែរ។ តារាងពិនិត្យប្រតិចារឹកនៃការស្តាប់សក្ខីកម្មដូចបានយោងក្នុង**ឧបសម្ព័ន្ធ I** នឹងបញ្ជាក់ពីអង្គហេតុនេះ។

៧៩- ឯកសារភ័ស្តុតាងមួយចំនួនធំដែលពាក់ព័ន្ធនឹងការអនុវត្តនយោបាយកម្ទេចខ្មាំង និងការប្រព្រឹត្តទៅនៃមន្ទីរស-២១ ក៏ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងដំណើរការនីតិវិធីសំណុំរឿង ០០២/០១ ផងដែរ។ ដូចបានបញ្ជាក់ក្នុង**ឧបសម្ព័ន្ធ I** ភ័ស្តុតាងទាំងនោះរាប់បញ្ចូលទាំងឯកសារដែលត្រូវបង្កើតឡើងនៅមន្ទីរស-២១ ប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុង សេចក្តីសម្រេច កំណត់ហេតុអង្គប្រជុំ និងឯកសារដែលមាននៅជំនាន់នោះ ដែលបង្ហាញភ័ស្តុតាងពីការអនុវត្តនយោបាយកម្ទេចខ្មាំង។ ភ័ស្តុតាងទាំងនេះត្រូវបានប្រើជាឯកសារយោង ឬបង្ហាញជូនសាក្សីដោយសហព្រះរាជអាជ្ញា មេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងផងដែរ។

៨០- រហូតមកដល់ពេលនេះ ដំណើរការនីតិវិធីបានដំណើរការទៅមុខយ៉ាងលឿនក្នុងការស្វែងរកការពិតអំពីការបង្កើត និងការវិវឌ្ឍន៍នយោបាយកម្ទេចខ្មាំងរបស់ បកក និងការអនុវត្តនយោបាយនេះ នៅតាមមន្ទីរសន្តិសុខនានា ដូចជានៅមន្ទីរស-២១ ជាដើម។ នយោបាយនេះជ្រាបចូលទៅក្នុងគ្រប់ទិដ្ឋភាពនៃ បកក និងរបបកម្ពុជាប្រជាធិបតេយ្យ រាប់បញ្ចូលទាំងក្នុងប្រវត្តិរបស់បក្ស រចនាសម្ព័ន្ធរដ្ឋបាល និងយោធារបស់របបនេះ ព្រមទាំងក្នុងតួនាទីរបស់ជនជាប់ចោទផងដែរ។ ភ័ស្តុតាងដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាភ័ស្តុតាងទូលំទូលាយ និងគួរឲ្យជឿជាក់បំផុត។ ភាគីទាំងអស់បានសួរដេញដោលភ័ស្តុតាងនេះយ៉ាងល្អិតល្អន់។ ការសួរដេញដោលភាគច្រើនបានពន្លាតយ៉ាងសមស្របពីអង្គហេតុដែលកម្រិតជាចាំបាច់ សម្រាប់បង្ហាញពីមូលដ្ឋានបទល្មើសតូចចង្អៀត ក្នុងក្របខ័ណ្ឌវិសាលភាពដើមនៃសំណុំរឿង០០២/០១។ ការដែលតុលាការបានធ្វើសវនាការស្តាប់ភ័ស្តុតាងទាំងនេះ ប៉ុន្តែខកខានមិនបានប្រើភ័ស្តុតាងនេះក្នុងជំនុំជម្រះ ដើម្បីបញ្ជាក់ពីបទឧក្រិដ្ឋមួយច្បាស់បំផុត និងឃោរឃៅបំផុតរបស់ បកក គឺជាការផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌ និងការដឹកនាំសវនាការដ៏ត្រឹមត្រូវ។ ដោយសារតែតុលាការមានលទ្ធភាពតិចតួចបំផុត ក្នុងការជំនុំជម្រះដំណាក់កាលទីពីរ ដែល

ជនជាប់ចោទអាចត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ និងស្រុក១២នោះ និងវិសាលភាពនីតិវិធីកំណត់ច្បាស់លាស់ ដែលចាំបាច់ត្រូវដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងនេះ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសយ៉ាងច្បាស់ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន តាមវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង។

៨១- ប្រសិនបើគ្មានការកែតម្រូវទេ កំហុសនេះអាចបន្ថយលទ្ធភាពនៃការវាយតម្លៃខាងបរិបទដ៏ត្រឹមត្រូវអំពីគោលបំណងនៃការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញដោយបង្ខំ និងការប្រហារជីវិតមនុស្សនៅទួលពោធិ៍ជ្រៃ ព្រមទាំងបន្ថយទំនាក់ទំនងទៅនឹងនយោបាយកម្មេចខ្លាំងផងដែរ។ ហេតុដូច្នេះ កំហុសនេះ សង្ស័យ បណ្តាលឲ្យមានការខូចខាត។

*V. អង្គជំនុំជម្រះសាលាដំបូងលើកសំអាងមិនត្រឹមត្រូវទៅលើការព្រួយបារម្ភពីសុខភាពរបស់ជនជាប់ចោទ*

៨២- សេចក្តីសម្រេចដែលរងការជំទាស់ក៏បានពឹងផ្អែកមួយផ្នែក ទៅលើការវាយតម្លៃពីការអូសបន្លាយពេលវេលាដែលបណ្តាលមកពីបញ្ហាសុខភាពរបស់ជនជាប់ចោទ ដែលបានកើតឡើង ក្នុងអំឡុងពេលជំនុំជម្រះ[134]។ តាមការពិនិត្យលើ "បញ្ហាប្រឈមក្នុងការដឹកនាំសវនាការ" ដែលបណ្តាលមកពីការសម្រាកព្យាបាលជម្ងឺរបស់ អៀង សារី ក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការពន្លាតវិសាលភាពសវនាការទៅដល់មន្ទីរស-២១ និងតាំងសម្លាប់មនុស្សស្រុក១២ អាចនឹងមិនមែនជា "ការអនុវត្តសមស្របនៃឆន្ទានុសិទ្ធិដឹកនាំសវនាការរបស់ខ្លួនទេ"[135]។

៨៣- សេចក្តីសម្រេចដែលរងការជំទាស់នេះ យោងទៅលើការវាយតម្លៃ និងការពិនិត្យឡើងវិញអំពីសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមក្នុងសវនាការ ដែលជាឧទាហរណ៍មួយនៃ"ដំណើរការយូរអង្វែង" កំពុងបណ្តាលឲ្យមានការពន្យារដំណើរការនីតិវិធី[136]។ ប៉ុន្តែ ខុសពីសំអាងហេតុនេះ តុលាការបានប្រើប្រាស់ពេលវេលាតែពីរថ្ងៃប៉ុណ្ណោះ ក្នុងការដោះស្រាយបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមក្នុងសវនាការ ចាប់តាំងពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីក្នុងសំណុំរឿង00២[137]។ ថ្ងៃទីពីរនៃសវនាការនោះបានប្រព្រឹត្តទៅដូចជាថ្ងៃសវនាការពិសេសរបស់តុលាការ គឺចំថ្ងៃសុក្រ[138] មាន

---

[134] E163/5 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២។

[135] E163/5 ដដែលដូចលើកយោងខាងលើ កថាខណ្ឌ ២។

[136] ឯកសារលេខ **E163/5** ដដែលដូចលើកយោងខាងលើ កថាខណ្ឌ ២។

[137] ចុះថ្ងៃទី៣០ និង៣១ ខែសីហា ឆ្នាំ២០១២។ ឯកសារលេខ **E1/118.1** ប្រតិចារឹកនៃដំណើរការនីតិវិធី ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២។

[138] ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ គឺជាថ្ងៃសុក្រ។

ន័យថា សវនាការលើសំណុំរឿង០០២/០១ ត្រូវបានពន្យារតែមួយថ្ងៃនៃថ្ងៃការងាររបស់តុលាការ។ សកម្មភាពបន្ថែមទៀតទាក់ទងទៅនឹងសម្បទារបស់ អៀង ធីរិទ្ធិ ដើម្បីចូលរួមក្នុងសវនាការ ដូចជាការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងការត្រៀមរៀបចំសវនាការ ត្រូវបានធ្វើឡើងនៅពេលដំណាលគ្នានឹងការជំនុំជម្រះនេះដែរ ហើយមិនបណ្តាលឲ្យមានការពន្យារណាមួយឡើយ។

៨៤- ត្រឡប់ទៅបញ្ហាដែលកំពុងតែកើតមានឡើងពីការសម្រាកនៅមន្ទីរពេទ្យនាពេលនេះរបស់ អៀង សារី វិញម្តង ការពិនិត្យឡើងវិញទៅលើកំណត់ហេតុសវនាការមកទល់នឹងថ្ងៃនេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់មានលទ្ធភាពសម្របសម្រួលការកែប្រែកម្មវិធីជំនុំជម្រះ ដើម្បីកាត់បន្ថយការអាក់ខានណាមួយដល់កម្រិតអប្បបរមា ធ្វើយ៉ាងណាឲ្យដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន។ ជាពិសេស អៀង សារី បានលះបង់សិទ្ធិមានវត្តមានរបស់គាត់ចំពោះការចោទសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន[139]។ យោងលើការលះបង់សិទ្ធិនេះ អង្គជំនុំជម្រះសាលាដំបូងនឹងមានលទ្ធភាពបន្តដំណើរការនីតិវិធីលើភ័ស្តុតាង ដោយមិនមានការពន្យារជាបន្តទៅទៀត រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០១២ ប្រសិនបើមិនយូរជាងនេះទៀតទេ ជាពិសេស ដោយយោងទៅលើសេចក្តីសម្រេចនាពេលថ្មីៗរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកាត់បន្ថយចំនួនថ្ងៃជំនុំជម្រះ[140]។ សាក្សីទាំងឡាយដែលសវនាការស្តាប់ចម្លើយរបស់គាត់ត្រូវបានពន្យារពេល ដោយសារមកពីការចូលសម្រាកនៅមន្ទីរពេទ្យរបស់ អៀង សារី ដែលសាក្សីទាំងនោះផ្តល់សក្ខីកម្មទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ និងរចនាសម្ព័ន្ធ និងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការលះបង់សិទ្ធិទូលំទូលាយត្រូវបានផ្តល់ដោយមេធាវីការពារក្តី អៀង សារី សម្រាប់សាក្សីដែលផ្តល់សក្ខីកម្មទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ដែលសវនាការនេះអាចបន្ត ប្រសិនបើទីតាំងឧក្រិដ្ឋកម្មនេះត្រូវបន្ថែម។

៨៥- ការផ្លាស់ប្តូរក្នុងពេលថ្មីៗនេះ ដែលងាកទៅរកសាក្សីទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម ក៏បានបញ្ជាក់ច្បាស់ផងដែរអំពីទីតាំងសំខាន់ ក្នុងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពង្រីកវិសាលភាពនៃសំណុំរឿង

[139] ឯកសារលេខ E236/1 ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលត្រូវស្តាប់សក្ខីកម្មនៅពេលសវនាការក្នុងផ្នែកការជម្លៀសប្រជាជននៅក្នុងបរិបទសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ឯកសារលេខE237 ពាក្យសុំលះបង់សិទ្ធិមានដែនកំណត់របស់ អៀង សារី ចំពោះមានវត្តមានក្នុងកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២។ ឯកសារលេខ E237/1 ពាក្យសុំលះបង់សិទ្ធិមានដែនកំណត់របស់ អៀង សារី ចំពោះវត្តមានក្នុងកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២។

[140] ឯកសារលេខ E1/128 ប្រតិចារឹក ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់ទំព័រ៨៦ បន្ទាត់១៨-២២ និងខ្លឹមសារខាងក្រោម សេចក្តីប្រកាសព័ត៌មាន “អង្គជំនុំជម្រះកាត់បន្ថយថ្ងៃធ្វើសវនាការប្រចាំសប្តាហ៍ ក្នុងសំណុំរឿងលេខ០០២/០១” ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ដែលមាននៅលើគេហទំព័រ៖http://www.eccc.gov.kh/en/articles/trial-chamber-reduces-number-weekly-hearing-days-case-0021។

លេខ០០២/០១ - ទីតាំងឧក្រិដ្ឋកម្មនោះ អាចត្រូវបានធ្វើការជំនុំជម្រះលើផ្នែកដែលពាក់ព័ន្ធបានដោយឆាប់រហ័ស។ ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៦០ ខាងលើ ភាគីនានាជាទូទៅបានទទួលពេលវេលាតែមួយថ្ងៃប៉ុណ្ណោះ (រួមគ្នា) សម្រាប់ការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមសវនាការស្តាប់ភស្តុតាងដែលទាក់ទងនឹងការជម្លៀសចេញដោយបង្ខំ នៅរសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ហើយនៅក្នុងរយៈពេល៦ថ្ងៃនៃថ្ងៃធ្វើសវនាការរបស់តុលាការ បានបញ្ចប់នូវការស្តាប់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧នាក់[141]។ នេះបានបង្ហាញថាភស្តុតាងសក្ខីកម្មបែបនេះ អាចត្រូវបញ្ចប់ក្នុងដំណាក់កាលមួយលឿនជាង ដំណាក់កាលស្តាប់សក្ខីកម្មសាក្សីដែលផ្តល់ភស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងនយោបាយរបស់របបនោះ។ ព្រឹត្តិការណ៍ទាំងនេះបង្ហាញឲ្យឃើញថែមទៀតអំពីកំហុសនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកម្រិតដាក់លាក់ចំពោះវិសាលភាពនៃទីតាំងឧក្រិដ្ឋកម្មដោយសារតែការពិចារណាអំពីរយៈពេលវែងនៃសវនាការ។

៨៦- ទោះជានៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ សហព្រះរាជអាជ្ញាសូមស្នើថា បញ្ហាពាក់ព័ន្ធនឹងសុខភាព និងអាយុរបស់ជនជាប់ចោទ គួរតែសម្របសម្រួលជាប្រយោជន៍ដល់ការរាប់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលបានស្នើសុំនៅក្នុងសំណុំរឿង០០២/០១ ជាជាងការជំទាស់ទៅវិញនោះ។ បញ្ហាសុខភាពដែលបានធ្វើឲ្យប៉ះពាល់ដល់ជនជាប់ចោទ ពីពេលមួយទៅពេលមួយ ក៏ដូចជា អាយុចាស់ជរារបស់ពួកគេ គឺជាការរំលឹកឡើងយ៉ាងច្បាស់ក្រឡែតថា ការជំនុំជម្រះជាបន្តទៅទៀតក្នុងសំណុំរឿង០០២ ទំនងជាមិនអាចប្រព្រឹត្តទៅបាននោះទេ។ ទោះបីជាសំណុំរឿង០០២/០២ អាចប្រព្រឹត្តទៅបានក៏ដោយ ក៏ពេលវេលាបន្ថែមដែលតម្រូវឲ្យមាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួន ពិតជាធានាអះអាងយ៉ាងច្បាស់នោះពិតជាបន្ថែមហានិភ័យអំពីបញ្ហាសុខភាព ដែលរារាំងមិនអាចឲ្យចេញសាលក្រមស្ថាពរបានឡើយ។ តាមពិតទៅ មូលហេតុប្រកបដោយហេតុផលបំផុតនោះគឺ សេចក្តីរំពឹងទុករបស់ស្ថាប័ន អ.វ.ត.ក ក្នុងការជំនុំជម្រះជនជាប់ចោទក្នុងសំណុំរឿង០០២/០១ ចំពោះបទចោទទាំងឡាយដែលអាចត្រូវបានសម្របសម្រួលសមហេតុសមផលបំផុត ដោយមានការពន្លាតពេលវេលាពាក់ព័ន្ធតិចតួចបំផុត ទៅលើពេលវេលាសវនាការ។ នេះពិតជាការពន្លាតពេលវេលាមានកម្រិតដែលសហព្រះរាជអាជ្ញាបានស្នើសុំដើម្បីឲ្យសម្រេចបានលទ្ធផល។

## V. ដំណោះស្រាយដែលបានស្នើសុំ

៨៧- យោងទៅលើមូលហេតុទាំងនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

[141] សាក្សី TCCP-169; TCCP-25; TCW-661; TCCP-64; TCW-362; TCW-690; និង TCCP-89។

*សំណុំរឿងលេខ:០០២/១៩-០៩-២០០៧-អវតក/អជតក*

១) **ទទួលយក**បណ្តឹងសាទុក្ខភ្លាមៗនេះ

២) **សម្រេច** ពង្រីកវិសាលភាពសវនាការក្នុងសំណុំរឿង០០២/០១ ដូចដែលសហព្រះរាជអាជ្ញាបានស្នើសុំ គឺដើម្បីផលប្រយោជន៍យុត្តិធម៌ និង

៣) **កែប្រែ** សេចក្តីសម្រេចដែលរងការជំទាស់នេះ ត្រូវដាក់បញ្ចូលមន្ទីរសន្តិសុខស-២១ (រួមទាំងទីតាំងសម្លាប់មនុស្សនៅជើងឯក) និងទីតាំងសម្លាប់មនុស្សក្នុងស្រុកកំពង់ត្រឡាចលើ (ស្រុក១២) ដែលឋិតនៅក្នុងវិសាលភាពនៃសវនាការលើសំណុំរឿង០០២/០១ ដូចដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា ក្នុងឯកសារ E163 និងណែនាំឱ្យអង្គជំនុំជម្រះសាលាដំបូង អនុវត្តវិសាលភាពនេះ ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងការគ្រប់គ្រងសវនាការរបស់ខ្លួន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |